## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍ឆ្លើយតបសំណួររបស់គណៈកម្មាធិការ សិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ពាក់ព័ន្ធនឹង របាយការណ៍លើកទី២ និង ទី៣ របស់កម្ពុជា ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ

ខែឧសភា ឆ្នាំ២០១១

រៀបចំដោយៈ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# ផ្នែកទី១

*សំណួរទី ០១- សូមផ្តល់ព័ត៌មានបច្ចុប្បន្នកម្មថ្មីៗស្តីពីជំហាននានាដែលរដ្ឋភាគីបានចាត់ក្នុងការរៀបចំបង្កើតឲ្យមានយន្តការឯករាជ្យមួយសម្រាប់តាមដានត្រួតពិនិត្យ ការបំពេញ(អនុវត្ត)សិទ្ធិកុមារ ស្របទៅតាមអនុសញ្ញាដែលអាចជាអង្គភាពកុមារមួយនៅក្នុងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិឬក៏ជាយន្តការដាច់ដោយឡែកមួយផ្សេង។*

**ចម្លើយ** :

១- រាជរដ្ឋាភិបាលកម្ពុជាមានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក) ជាសេនាធិការក្នុងការតាមដានត្រួតពិនិត្យការអនុវត្តសិទ្ធិកុមារ។ អគ្គលេខាធិការដ្ឋានក.ជ.ក មានអង្គភាពជំនាញមួយហៅថា ផ្នែកការពារកុមារនិងពិនិត្យតាមដានដែលមានតួនាទីភារកិច្ចពិនិត្យតាមដាន វាយតម្លៃនិងធ្វើរបាយការណ៍លើការអនុវត្តគោលនយោបាយ និងកម្មវិធីជាតិនិងបទដ្ឋានអន្តរជាតិផ្សេងៗពាក់ព័ន្ធនឹងកុមារ ពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ។

២- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាធ្វើការត្រួតពិនិត្យតាមដាន ការអនុវត្តសិទ្ធិមនុស្សជាទូទៅដែលក្នុងនោះមានទាំងការអនុវត្តសិទ្ធិកុមារផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាបានឯកភាពជាគោលការណ៍ឲ្យបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សឯករាជ្យមួយដែលមានតួនាទីត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។

៣- រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតយន្តការថ្នាក់ជាតិដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញឬទណ្ឌកម្ម ដើម្បីធានាគោរពសិទ្ធិជាមូលដ្ឋានរបស់ជនដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅតាមទីកន្លែងឃុំឃាំង។ ក្រសួងយុត្តិធម៌បានចេញប្រកាសលេខ ៥៨ កយប្រក/០៦ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០០៦ បង្កើតក្រុមការងារយុត្តិធម៌កុមារដែលមានសមាសភាពមកពីក្រសួងចំនួន០៥ ដើម្បីរៀបចំប្រព័ន្ធយុត្តិធម៌កុមារមេត្រីនិងធ្វើសេចក្តីព្រាងច្បាប់ និងបទបញ្ញាទាក់ទងនឹងវិស័យយុត្តិធម៌កុមារ។

៤- ក្នុងខែមិថុនា ឆ្នាំ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងតុលាការ បានឯកភាពលើគម្រោងមួយដែលផ្តួចផ្តើមនិងរៀបចំនូវក្របខណ្ឌទស្សនាទានសម្រាប់ការបង្កើតគណៈកម្មាធិការឃ្លាំមើល (Ombudsman) នៅព្រះរាជាណាចក្រកម្ពុជា។

*សំណួរទី ០២ - សូមបញ្ជាក់ថា តើអង្គការមិនមែនរដ្ឋាភិបាល រួមទាំងអង្គការសិទ្ធិមនុស្សផងដែរ មានបានប្រមូលផ្តុំគ្នាជាដៃគូដ៏មានប្រសិទ្ធភាពនៅគ្រប់ដំណាក់កាលនៃការអនុវត្តអនុសញ្ញាដែរឬទេ។ សូមផ្តល់ព័ត៌មានផងដែរអំពីសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងបំភ្លឺថាតើច្បាប់នេះនឹងអនុញ្ញាតឲ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ នៅក្នុងការអនុវត្តអនុសញ្ញានេះដែរឬទេ?*

**ចម្លើយ** :

១- រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកសង្គមស៊ីវិលជាដៃគូដ៏សំខាន់មួយក្នុងចំណោមដៃគូសំខាន់ទាំង ០៣ : សង្គមស៊ីវិល ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍។ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិជាច្រើន បំពេញតួនាទីដ៏សកម្ម និងប្រកបដោយការយកចិត្តទុកដាក់នៅក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ក៏ដូចជាការជំរុញការលើកស្ទួយសិទ្ធិមនុស្ស ជាពិសេសការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។

អង្គភាពរបស់រដ្ឋដែលមានអង្គការមិនមែនរដ្ឋាភិបាលចូលរួមអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ មានជាអាទិ៍ :

- ក្រុមការងារទាំង០៦របស់គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ
- ក្រុមការងារសមាហរណកម្មនិងតាមដានបន្ត
- ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រានិងកុមារងាយរងគ្រោះ
- ក្រុមប្រឹក្សាសកម្មភាពជនពិការ និង
- អនុគណៈកម្មការនិងក្រុមការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

នៅក្នុងវិស័យការពារកុមារ សង្គមស៊ីវិលបានដើរតួយ៉ាងសំខាន់នៅក្នុងការផ្តល់សេវាថែទាំ និងការពារកុមារងាយរងគ្រោះនិងគ្រួសាររបស់ពួកគេ។ នៅក្នុងឆ្នាំ២០១០ មានអង្គការមិនមែនរដ្ឋាភិបាលចំនួន២៩០ ដែលមានឈ្មោះនៅក្នុងបញ្ជីធនធានសេវាសម្រាប់កុមារងាយរងគ្រោះរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ ) ដែលបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១០។

២- តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលបានចូលរួមនៅក្នុងវេទិកាសហប្រតិបត្តិការនិងការពិគ្រោះយោបល់ជាន់ខ្ពស់ និងការពិគ្រោះយោបល់ផ្នែកច្បាប់ជាច្រើន ដូចជា :

- ក្រុមការងារយុត្តិធម៌កុមារ ចំរុះរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល
- ក្រុមការងារសរសេររបាយការណ៍ស្តីពីការអនុវត្តពិធីសារនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ល។
- វេទិកាសហប្រតិបត្តិការអភិវឌ្ឍកម្ពុជា
- ការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ល។

៣- អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានអនុវត្តដោយមានការចូលរួមពីដៃគូទាំងបី រួមទាំងគ្រួសារ និងសហគមន៍ប្រកបដោយប្រសិទ្ធិភាព និងទទួលបានសមិទ្ធិផលជាច្រើនដូចមានបង្ហាញជូននៅក្នុងសេចក្តីលម្អិតនៃរបាយការណ៍លើកទី២និងទី៣ ដែលបានដាក់ជូនកន្លងមកនិងនៅក្នុងការឆ្លើយតបនឹងសំណួរនេះ។

៤- យោងតាមសេចក្ដីព្រាងច្បាប់ស្ដីពីសមាគមន៍និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានដាក់ជូនអង្គពិគ្រោះយោបល់នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ច្បាប់នេះមានគោលបំណងផ្ដល់ឱកាសឲ្យសមាគមន៍និងអង្គការមិនមែនរដ្ឋាភិបាល(ក្នុងស្រុកនិងអន្ដរជាតិ) ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តគម្រោងនិងកម្មវិធីដើម្បីអភិវឌ្ឍសង្គមកម្ពុជា ក៏ដូចជារួមចំណែកអនុវត្តអនុសញ្ញាស្ដីពីសិទ្ធិកុមារផងដែរ។ ច្បាប់នេះមិនដាក់កំហិតលើការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្ដរជាតិ នៅក្នុងការអនុវត្តសន្ធិសញ្ញាអន្ដរជាតិណាមួយដែលព្រះរាជាណាចក្រកម្ពុជាបានឲ្យសច្ចាប័ននោះទេជាពិសេសអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

*សំណួរទី ០៣ - សូមបញ្ជាក់អំពីវិធានការដែលបានប្រកាន់យក ដើម្បីឆ្លើយតបនឹងភាពខុសគ្នា(គម្លាត) រវាងកុមាររស់នៅតាមទីប្រជុំជន ជាមួយនឹងកុមាររស់នៅតាមទីជនបទ និងរវាងកុមាររស់នៅក្នុងខេត្តផ្សេងៗគ្នាក្នុងទូទាំងប្រទេសក្នុងការទទួលបាននូវសិទ្ធិរបស់ខ្លួន ជាពិសេសគឺសិទ្ធិទទួលបាននូវបទដ្ឋានសមស្រប ក្នុងការរស់នៅ ខាងសុខភាព ការអប់រំ និងលទ្ធភាពទទួលបាននូវសេវាសង្គមកិច្ច។*

**ចម្លើយ** :

១- រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល បាននិងកំពុងប្រឹងប្រែងកាត់បន្ថយគម្លាតនៃការរស់នៅរបស់កុមាររស់នៅតាមទីប្រជុំជន ជាមួយនឹងកុមាររស់នៅតាមទីជនបទ ដោយទទួលបានលទ្ធផលគួរជាទីមោទនៈ ក៏ប៉ុន្ដែនៅមានគម្លាតសេដ្ឋកិច្ចរវាងប្រភេទកុមាររស់នៅតាមទីប្រជុំជន និងកុមាររស់នៅតាមជនបទនៅឡើយ។

២- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ បានលើកឡើងនូវគោលនយោបាយអាទិភាពសំខាន់ៗដែលទាក់ទងនឹងកុមារ។ ចំពោះព័ត៌មានលំអិតសូមមើលឧបសម្ព័ន្ធលេខ០២។ ទាក់ទងនឹងការពង្រឹងគុណភាពវិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ក្នុងការអនុវត្តផែនការជាតិ " អប់រំសម្រាប់ទាំងអស់គ្នា " តាមរយៈការធានាសមធម៌ក្នុងការអប់រំមូលដ្ឋានរយៈពេល០៩ឆ្នាំសម្រាប់កុមារគ្រប់រូប។ សមិទ្ធិផលសំខាន់រួមមានចំនួនសាលារៀន និងគ្រូបង្រៀន ព្រមទាំងការចុះឈ្មោះចូលរៀននៅគ្រប់កម្រិតសិក្សានៃចំណោះទូទៅបានកើនឡើងជាលំដាប់ ជាពិសេសនៅតាមតំបន់ជនបទ។ ដោយឡែកអនុវិទ្យាល័យត្រូវបានបង្កើតឡើងនៅស្ទើរគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនថវិកាជាច្រើនសម្រាប់វិស័យអប់រំ ។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្ដោតទៅលើការផ្ដល់ឱកាសស្មើៗគ្នាដល់កុមារនិងយុវជនទាំងអស់ ក្នុងការទទួលបានការអប់រំមូលដ្ឋានក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ កំណើត និងឋានៈក្នុងសង្គមឡើយ។

ទាក់ទងទៅនឹងវិស័យសុខាភិបាល រាជរដ្ឋាភិបាលកម្ពុជាបានផ្ដោតការយកចិត្តទុកដាក់ទៅលើ

ការលើកកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋជាទូទៅ ជាពិសេសប្រជារាស្ត្រក្រីក្រ ស្ត្រី និងកុមារ។ ការអនុវត្តសំណុំសកម្មភាពអប្បរមាកំពុងមានវឌ្ឍនភាពល្អ។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ក្នុងគោលដៅកាត់បន្ថយអត្រាស្លាប់របស់មាតានិងទារកនិងកែលម្អសូចនាករសុខាភិបាលសំខាន់ៗផ្សេងទៀត តាមរយៈការពង្រឹងគុណភាពនិងពង្រីកសេវាសុខាភិបាល ជាពិសេសសេវាសុខភាពបន្តពូជ សេវាសុខភាពមាតានិងសេវាសុខភាពទារកនិងកុមារ។ គោលដៅមួយក្នុងចំណោមការលើកកម្ពស់សេវាសុខភាពនោះ គឺការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់មាតានិងកុមារ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ទៅលើ :

- ការអនុវត្តកម្មវិធីបង្ការនិងព្យាបាលជំងឺឆ្លងនានា សាងសង់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពទូទាំងប្រទេស ដែលអាចផ្គត់ផ្គង់សេវាសុខាភិបាលមូលដ្ឋានប្រកបដោយប្រសិទ្ធភាពចីរភាពសមធម៌ និងបង្កើនគុណភាពវិជ្ជាជីវៈ។
- ការបង្កើនប្រាក់លើកទឹកចិត្តសម្រាប់បុគ្គលិកសុខាភិបាលនៅតំបន់ជនបទ និងបង្កើនចំនួនវេជ្ជបណ្ឌិត គ្រូពេទ្យ និងពេទ្យឆ្មប
- ការអប់រំផ្សព្វផ្សាយព័ត៌មានសុខាភិបាល អនាម័យឱ្យបានទូលំទូលាយ ជាពិសេសដល់តំបន់ជនបទ
- ការផ្តល់សេវាដល់ជនក្រីក្រ តាមរយៈមូលនិធិសមធម៌ និងប្រព័ន្ធធានារ៉ាប់រងសុខភាព។

ទន្ទឹមនេះរាជរដ្ឋាភិបាលកម្ពុជាបានបង្កើនថវិកាជាច្រើនសម្រាប់វិស័យសុខាភិបាល។ ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភ ដែលមានក្រសួងផែនការជាប្រធានសហការជាមួយបណ្តាក្រសួងដែលពាក់ព័ន្ធ និងអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន កំពុងបន្តជំរុញការអនុវត្តផែនការសកម្មភាពសម្រាប់កម្មវិធីបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារឆ្នាំ២០១១ ក្នុងគោលបំណងលុបបំបាត់បញ្ហាជំងឺកង្វះមីក្រូសារជាតិ និងបន្តពង្រីកការផ្សព្វផ្សាយអនុក្រឹត្យទាក់ទងនឹងអំបិលអ៊ីយ៉ូដ។ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ៥២ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ កំណត់យកថ្ងៃទី១៣ ខែវិច្ឆិកា ទុកជាទិវាជាតិលើកកម្ពស់អនាម័យជនបទ។

សកម្មភាពទាំងនេះចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភចំពោះស្ត្រីនិងកុមារ ជាពិសេសស្ត្រីនិងកុមារដែលរស់នៅតំបន់ជនបទ។

រាជរដ្ឋាភិបាលបាននឹងកំពុងកសាងហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ដឹកជញ្ជូន ផ្លូវ ស្ពាន ផ្លូវលំជនបទសម្រួលការធ្វើចរាចរណ៍របស់ប្រជាពលរដ្ឋ និងអណ្តូងទឹកស្អាតរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។

រាជរដ្ឋាភិបាល បានអនុម័តគោលនយោបាយស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច នៅក្នុងខែមេសា ឆ្នាំ២០០៩ ក្នុងគោលបំណងសំដៅ:

- លើកកម្ពស់កម្រិតជីវភាពរបស់ជនជាតិដើមភាគតិច

- ធានាថាពួកគេទទួលបាននូវការអប់រំយ៉ាងតិចចំនួន៩ឆ្នាំ ព្រមទាំងការបណ្តុះបណ្តាលអំពីបំណិនជីវិតផងដែរ
- ធ្វើឲ្យសុខភាពរបស់ពួកគេកាន់តែល្អប្រសើរឡើង និង
- ការពារថែរក្សាវប្បធម៌របស់ជនជាតិដើមភាគតិច ។

៣- មានការផ្តួចផ្តើមគំនិតមួយចំនួននៅក្នុងការរៀបចំឲ្យមានប្រព័ន្ធការពារកុមារមួយឡើងនៅកម្ពុជា។ នៅក្រោមការដឹកនាំរបស់ក្រសួង ស.អ.យ និងដោយមានការគាំទ្រពីអង្គការមូលនិធិសម្រាប់កុមាររបស់អង្គការសហប្រជាជាតិ(UNICEF) បណ្តាញការពារកុមារត្រូវបានបង្កើតនៅក្នុងខេត្តចំនួន០៩។ ថ្នាក់ឃុំ សង្កាត់បានទទួលការគាំទ្រកាន់តែកើនឡើងនៅក្នុងដំណើរការវិមជ្ឈការនិងវិសហមជ្ឈការ ពីព្រោះគឺថ្នាក់នេះឯងដែលមានតួនាទីនិងភារកិច្ចថែទាំនិងការពារកុមារ។ ជាក់ស្តែងដូចជា អង្គការសង្គ្រោះកុមារ(Save the Children) បានផ្តល់ការគាំទ្រដល់ការកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ។ ចំណែកឯអង្គការទស្សនៈពិភពលោក(World Vision) វិញ បានផ្តល់ការគាំទ្រទៅដល់ថ្នាក់ភូមិ នៅក្នុងការបង្កើតមូលនិធិភូមិ សម្រាប់ការថែទាំនិងការពារកុមារងាយរងគ្រោះនិងគ្រួសារ។ អង្គការមួយចំនួនទៀតបានឈានមុខគេនៅក្នុងការលើកកម្ពស់ការថែទាំកុមារក្នុងគ្រួសារ និងក្នុងសហគមន៍ ដូចជាអង្គការមិត្តសំលាញ់អន្តរជាតិ(Friends International) អង្គការមិត្តសំលាញ់និងអង្គការទស្សនៈពិភពលោកជាដើម។ សេចក្តីព្រាងប្រកាសមួយស្តីពីនីតិវិធីនៃការអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារត្រូវបានរំពឹងថានឹងជួយរៀបចំបង្កើតឲ្យមានប្រព័ន្ធសុខមាលភាពកុមារមួយឡើង តាមរយៈការកំណត់តួនាទីនិងភារកិច្ចរបស់គ្រប់ថ្នាក់ទាំងអស់ និងការផ្តល់ជូននូវការណែនាំច្បាស់លាស់អំពីរបៀបទុកដាក់កុមារដោយយោងទៅតាមឧត្តមប្រយោជន៍របស់គេ។ វិស័យមួយទៀតដែលមានការគាំទ្រច្រើនផងដែរដោយដៃគូអភិវឌ្ឍដូចជាអង្គការយូនីសេហ្វ អង្គការចិត្តសង្គមអន្តរវប្បធម៌(TPO) សេវាសង្គមកិច្ចកម្ពុជា(SSC) ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត គឺការកសាងសមត្ថភាពរបស់មន្ត្រីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលនិងបុគ្គលិកសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល។

៤. ការបង្កើតឡើងនូវគណៈកម្មការពិគ្រោះយោបល់សម្រាប់ស្ត្រីនិងកុមារ និងគណៈកម្មការឃុំ/សង្កាត់សម្រាប់ស្ត្រីនិងកុមារគឺជាការបោះជំហានទៅមុខមួយជំហានយ៉ាងធំរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការលើកកម្ពស់ប្រព័ន្ធការពារកុមារនៅថ្នាក់ខេត្ត ស្រុក និងឃុំសង្កាត់។ ដោយក្រសួង ស.អ.យ មិនមានរចនាសម្ព័ន្ធនិងមុខងារអ្វីទេនៅថ្នាក់ឃុំ/សង្កាត់ គណៈកម្មការឃុំ/សង្កាត់សម្រាប់ស្ត្រីនិងកុមារមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការបំពេញកាតព្វកិច្ចជាអ្នកសង្គមកិច្ចម្នាក់នៅក្នុងការកំណត់អត្តសញ្ញាណ ការប៉ាន់ប្រមាណ ការផ្តល់សេវាបន្ទាន់ ការតាមដានស្ថានភាពស្ត្រីនិងកុមារ និងការតាមដានករណីបន្តផងដែរតាមដែលអាចធ្វើទៅបាន។ សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការអនុវត្ត

គោលនយោបាយថែទាំជំនួសចំពោះកុមារក៏មានលើកផងដែរអំពីតួនាទីនិងភារកិច្ចរបស់គណៈកម្មការពិគ្រោះយោបល់សម្រាប់ស្ត្រីនិងកុមារ និងគណៈកម្មការឃុំ/សង្កាត់សម្រាប់ស្ត្រីនិងកុមារនេះ។

៥. យុទ្ធសាស្ត្រជាតិស្តីពីការការពារផ្នែកសង្គមកិច្ចចំពោះជនក្រីក្រនិងជនងាយរងគ្រោះត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៅក្នុងការពន្លឿនការរីកចម្រើនឆ្ពោះទៅរកការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរបស់កម្ពុជា។ យុទ្ធសាស្ត្រនេះបានផ្តល់អាទិភាពទៅឲ្យការអភិវឌ្ឍឡើងនូវបណ្តាញសុវត្ថិភាពសង្គមមួយដែលប្រកបទៅដោយប្រសិទ្ធភាពនិងស្ថិតស្ថេរសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ក្នុងនោះមានទាំងកុមារផងដែរ។ នៅក្នុងខែមិថុនា ឆ្នាំ២០០៨ ក្រសួង ស.អ.យ បានរៀបចំបង្កើតផែនការសកម្មភាពជាតិសម្រាប់កុមារកំព្រានិងកុមារងាយរងគ្រោះឆ្នាំ២០០៨ ដល់២០១០ឡើង ដើម្បីផ្តល់ក្របខ័ណ្ឌមួយដល់ការសម្របសម្រួលខាងវិធីសាស្ត្រនិងសេវាសម្រាប់កុមារកំព្រានិងកុមារងាយរងគ្រោះ។ ផែនការសកម្មភាពនេះត្រូវបានពិនិត្យមើលឡើងវិញ និងពន្យារបន្តរហូតទៅដល់ឆ្នាំ២០១៥។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការឆ្លើយតបសមស្រប និងពហុវិស័យទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ឆ្នាំ២០១០ដល់២០១៥ ត្រូវបានអភិវឌ្ឍឡើងដោយរួមមានទាំងយុទ្ធសាស្ត្របង្ការការចម្លងមេរោគអេដស៍ក្នុងចំណោមយុវវ័យ និងការកាត់បន្ថយផលប៉ះពាល់ចំពោះ កុមារកំព្រានិងកុមារងាយរងគ្រោះផងដែរ សមស្របទៅតាមគោលដៅអភិវឌ្ឍសហស្សវត្សរបស់កម្ពុជា។

***សំណួរទី ០៤ - សូមផ្តល់ព័ត៌មានលំអិតអំពីវិធានការដែលបានប្រកាន់យកដើម្បីលុបបំបាត់ឥរិយាបទដែល ធ្លាប់មានតាមប្រពៃណីដែលធ្វើឲ្យមានការរើសអើងយូរយារណាស់មកហើយចំពោះកុមារី និងឲ្យមានអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងរដ្ឋភាគី ។ ចំពោះបញ្ហានេះ សូមបំភ្លឺថា តើក្រមសីលធម៌តាមប្រពៃណីដែលមានឈ្មោះថា " ច្បាប់ស្រី " នោះ នៅតែមាននៅក្នុងកម្មវិធីសិក្សាតាមសាលារៀនដដែលឬយ៉ាងណា ? ។***

**ចម្លើយ** :

១- ព្រះរាជាណាចក្រកម្ពុជាមិនបានដាក់បញ្ចូល " ច្បាប់ស្រី " ទៅក្នុងកម្មវិធីសិក្សាតាមសាលារៀនទេ។

២- វិធានការដើម្បីលុបបំបាត់ឥរិយាបទដែលធ្លាប់មានតាមប្រពៃណីដែលអាចធ្វើឲ្យមានការរើសអើងចំពោះកុមារី និងឲ្យមានអំពើហិង្សាផ្អែកលើយេនឌ័រមាន :

ក- បានរៀបចំឲ្យមានបណ្តាញក្រុមការងារតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ភូមិ ដើម្បីធ្វើការអប់រំផ្សព្វផ្សាយ ដូចខាងក្រោម :

**កម្មវិធីអប់រំមាតាបិតានិងគ្រួសារ** : ជួយជំរុញមាតាបិតាឲ្យយកចិត្តទុកដាក់ថែទាំ អប់រំកូននិងជំរុញឲ្យបញ្ជូនកូនទៅរៀនឲ្យបានស្មើភាពគ្នារវាងកូនស្រីនិងកូនប្រុស។ កម្មវិធីនេះអនុវត្តចាប់តាំងពីឆ្នាំ២០០៧ ក្នុងខេត្តគោលដៅចំនួន០៦ គឺ ខេត្តព្រៃវែង ស្វាយរៀង កំពង់ធំ កំពង់ស្ពឺ ស្ទឹងត្រែង និង

ខេត្តឧត្តរមានជ័យ។

**កម្មវិធីកែប្រែស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ស្ត្រី** ៖ នៅឆ្នាំ២០០៦ អនុវត្តកម្មវិធីនេះក្នុងខេត្តគោលដៅចំនួន០៦ គឺខេត្តបន្ទាយមានជ័យ ព្រះវិហារ មណ្ឌលគិរី កំពង់ធំ កំពង់ឆ្នាំង និងខេត្តតាកែវ។ ក្នុងឆ្នាំ២០០៩ អនុវត្តក្នុងរាជធានី ខេត្តគោលដៅចំនួន០៥ គឺ រាជធានីភ្នំពេញ ខេត្តបាត់ដំបង កំពង់ចាម ព្រៃវែង និងស្វាយរៀង ។

**ខ-** វិធានការដើម្បីលុបបំបាត់ឥរិយាបទ ដែលធ្លាប់មានតាមប្រពៃណីដែលអាចធ្វើឲ្យមានអំពើហិង្សាផ្អែកលើយេនឌ័រមាន ៖

- ការបញ្ជ្រាបគោលការណ៍សមភាពយេនឌ័រទៅក្នុងគ្រប់មជ្ឈដ្ឋាន រួមមានប្រជាពលរដ្ឋ ក្រសួង ស្ថាប័ន មន្ទីររាជធានី ខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយមូលដ្ឋាន និងកម្មវិធីអភិវឌ្ឍនានា ដោយបង្កើនសមាសភាពស្ត្រីនៅក្នុងតួនាទីធ្វើសេចក្ដីសម្រេចនិងរៀបចំគោលនយោបាយ ។
- ការអប់រំ ផ្សព្វផ្សាយ អំពីវប្បធម៌អហិង្សា និងបំបាត់ការរើសអើងលើស្ត្រីតាមរយៈការធ្វើវេទិកាតាមវិទ្យុ និងតាមទូរទស្សន៍ ជាអាទិ៍។
- ការបង្កើតច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។
- ការផ្ដល់សេវាដល់ជនរងគ្រោះដូចជាជួយរកសេវាផ្នែកច្បាប់ សេវាសុខភាពនិងសេវាផ្នែកអប់រំផ្លូវចិត្តជាដើម ។

***សំណួរទី ០៥ - សូមផ្ដល់ព័ត៌មានថ្មីៗ ជូនគណៈកម្មាធិការអំពីវិធានការដែលបានប្រកាន់យក ដើម្បីធានាថាកុមារដែលមានដើមកំណើតជាវៀតណាម ឬកុមារមកពីជនជាតិភាគតិច បានចុះសំបុត្រកំណើត បន្ទាប់ពីបានចាប់កំណើត និងបានទទួលនូវឯកសារទាក់ទងនឹងអត្តសញ្ញាណ។ សូមផ្ដល់ព័ត៌មានផងដែរអំពីស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចនិងការរស់នៅរបស់កុមារទាំងអស់នោះ ក៏ដូចជាលទ្ធភាពអាចទទួលបាននូវសេវាសុខភាព អប់រំ និងសង្គមកិច្ច។***

**ចម្លើយ** ៖

គិតពីឆ្នាំ២០០២ មកទល់ឆ្នាំ២០១០ ប្រជាជនដែលបានចុះសំបុត្រកំណើតនិងសំបុត្របញ្ជាក់កំណើតមានដូចខាងក្រោម ៖

| ការចុះសៀវភៅកំណើត និងសៀវភៅបញ្ជាក់កំណើតទូទាំងប្រទេស | | | | |
|---|---|---|---|---|
| **ឆ្នាំ** | **សរុប** | **សំបុត្រកំណើត** | **សំបុត្របញ្ជាក់កំណើត** | **សំគាល់** |
| ឆ្នាំ២០០២ | ៣៤២ ៧៥៣ | ៣៣ ៣៤០ | ៣០៩ ៤១៣ | សំបុត្រកំណើតផ្ដល់ជូនជន |
| ឆ្នាំ២០០៣ | ១៨៣ ៣៩០ | ១១ ៤១៤ | ១៧១ ៩៧៦ | |

| | | | | |
|---|---|---|---|---|
| ខែមករា ដល់ខែកញ្ញា ឆ្នាំ២០០៤ | ៨ ០៦៧ ០៣៣ | ៣៤៧ ៦៥៣ | ៧ ៧១៩ ៣៨០ | ដែលបានចុះកំណើតក្នុងអំឡុងពេលមួយខែក្រោយពេលកើត។ សំបុត្របញ្ជាក់កំណើតផ្តល់ជូនជនដែលចុះកំណើតបន្ទាប់ពីអំឡុងពេលមួយខែក្រោយពេលកើត។ |
| ខែតុលា ឆ្នាំ២០០៤ដល់ខែសីហា ឆ្នាំ២០០៥ | ២ ៧១៤ ២៤៨ | ២៤៨ ៧៦៨ | ២ ៤៦៥ ៤៨០ | |
| ខែកញ្ញា ឆ្នាំ២០០៥ ដល់ខែ សីហា ឆ្នាំ២០០៦ | ៣២៦ ០៩៨ | ៦៥ ១១៤ | ២៦០ ៩៨៤ | |
| ខែមករា ដល់ខែធ្នូ ឆ្នាំ២០០៧ | ១៤៨ ២៦១ | ៥៩ ០៧៧ | ៨៩ ១៨៤ | |
| ខែមករា ដល់ខែធ្នូ ឆ្នាំ២០០៨ | ៨០៥ ១២៣ | ៩២ ៩៥៨ | ៧១២ ១៦៥ | |
| ខែមករា ដល់ខែធ្នូ ឆ្នាំ២០០៩ | ២៩៤ ៦៣៣ | ៩៨ ៧២២ | ១៩៥ ៩១១ | |
| ខែមករា ដល់ខែតុលា ឆ្នាំ២០១០ | ២៣១ ៧៨១ | ៧១ ៥៣៤ | ១៦០ ២៤៧ | |
| **សរុប** | **១៣ ១១៣ ៣២០** | **១ ០២៨ ៥៨០** | **១២ ០៨៤ ៧៤០** | |

ចំពោះកុមារជាជនជាតិភាគតិច ការចុះសំបុត្រកំណើតត្រូវបានធ្វើបន្ទាប់ពីបានចាប់កំណើត ដូចជាកុមារកម្ពុជាផ្សេងៗទៀតទូទាំងប្រទេសដែរ។

ព្រះរាជាណាចក្រកម្ពុជានៅមិនទាន់បានរៀបចំច្បាប់ពិសេស ដើម្បីកំណត់អំពីនីតិវិធីចុះអត្រានុកូលដ្ឋានកំណើតឲ្យកុមារដែលពុំមានសញ្ជាតិខ្មែរនៅឡើយទេ។ ឈរលើមូលដ្ឋាននៃការអនុវត្តជាក់ស្តែង ឯកសារទាក់ទងនឹងអត្តសញ្ញាណរបស់ឪពុកម្តាយរបស់កុមារប្រភេទនេះ ត្រូវបានផ្តល់ដោយគ្រូពេទ្យនាទីកន្លែងដែលកុមារកើត ។

បទប្បញ្ញត្តិមាត្រា៩៨៥ ស្តីពីករណីកិច្ចនៃការសុំចុះកំណើតនៃក្រមរដ្ឋប្បវេណី មិនបានដាក់កំហិត និងដាក់លក្ខខណ្ឌសញ្ជាតិលើឪពុកម្តាយក្នុងការសុំចុះកំណើតឲ្យកូននោះឡើយ។

ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច និងការរស់នៅរបស់កុមារដែលមានដើមកំណើតជាជនជាតិវៀតណាមក៏ដូចជាលទ្ធភាពអាចទទួលបាននូវសេវាសុខភាព អប់រំ និងសង្គមកិច្ចមិនមានអ្វីខុសប្លែកពីស្ថានភាពរបស់កុមារកម្ពុជាទូទៅឡើយ។ ដោយឡែកកុមារជនជាតិភាគតិចនៅទទួលផលប៉ះពាល់នៃគម្លាតសេដ្ឋកិច្ចនៅឡើយ ទោះបីជាក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះស្ថានភាពទូទៅរបស់កុមារនិងស្ត្រីក្នុងព្រះរាជាណាចក្រកម្ពុជាមានការរីកចម្រើនយ៉ាងប្រសើរក្តី។

ដើម្បីពង្រឹងការងារអត្រានុកូលដ្ឋាន ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ០២៩ សណន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយធ្វើការណែនាំដល់គណៈអភិបាលរាជធានីខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ដែលជាមន្ត្រីអត្រានុកូលដ្ឋាន និងមន្ត្រីទទួល បន្ទុកការងារអត្រានុកូលដ្ឋានគ្រប់ថ្នាក់ធ្វើការត្រួតពិនិត្យនិងយកចិត្តទុកដាក់កែលម្អការងារអត្រានុកូលដ្ឋាន។

*សំណួរទី ០៦ - សូមផ្តល់ព័ត៌មានជូនគណៈកម្មាធិការអំពីកម្មវិធីផ្នែកសង្គមកិច្ចដែលមាននៅក្នុងការជួយគាំទ្រគ្រួសារ ជាពិសេសគឺកម្មវិធីសំដៅបណ្តុះបណ្តាលមាតាបិតាអំពីការបំពេញតួនាទីទទួលខុសត្រូវជាមេបារបស់ពួកគាត់។*

**ចម្លើយ** :

១- រាជរដ្ឋាភិបាលបានចេញអនុក្រឹតលេខ៤៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០៥ ស្តីពីទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា។ ក្រសួង ស.អ.យ បានចេញប្រកាសលេខ ៣៧៩ ស.អ.យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិពិគ្រោះយោបល់គោលនយោបាយចំពោះគ្រួសារ។

២- ក្រៅពីការចេញសារលិខិតជារៀងរាល់ឆ្នាំដោយប្រមុខរាជរដ្ឋាភិបាល ក្រសួង ស.អ.យ បានរៀបចំទិវាអន្តរជាតិស្តីពីគ្រួសារ១៥ ឧសភា រៀងរាល់ឆ្នាំ ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល អ្នកតំណាងគ្រួសារ កម្មករ ពាណិជ្ជករ មន្ត្រីរាជការនិងនិវត្តន៍ជន។ ពិធីនេះ ចែករំលែកបទពិសោធន៍របស់អ្នកតំណាងគ្រួសារទាក់ទងនឹងការអប់រំបណ្តុះបណ្តាលកូនចៅការកសាងជីវភាពរស់នៅសាមគ្គីភាពនិងសីលធម៌រស់នៅ។ មន្ទីរ ស.អ.យ រាជធានី ខេត្ត ទូទាំងប្រទេសក៏ប្រារព្ធពិធីនេះរៀងរាល់ឆ្នាំដែរ។

៣- ក្រសួង ស.អ.យ កំពុងតែខិតខំពង្រឹងប្រព័ន្ធសុខមាលភាពកុមារតាមរយៈការអភិវឌ្ឍនិងអនុវត្តសាកល្បងនូវសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារដែលរួមមានទាំងអន្តរាគមន៍រក្សាកុមារនៅក្នុងគ្រួសារ និងការបង្រួបបង្រួមគ្រួសារផងដែរ។ បច្ចុប្បន្ននេះ ក្រសួង ស.អ.យ យកចិត្តទុកដាក់លើការចិញ្ចឹមថែទាំកុមារនៅតាមគ្រួសារតាមរយៈកម្មវិធីផ្តល់សេវាដល់គ្រួសារក្រីក្រ។

*សំណួរទី ០៧ - សូមផ្តល់ព័ត៌មានស្តីពីការចុះបញ្ជីគ្រឹះស្ថានដែលផ្តល់សេវាស្នាក់នៅនិងបញ្ជាក់ថាតើអាជ្ញាធរណាមួយដែលទទួលខុសត្រូវលើការចិញ្ចឹមទុកដាក់ និងតាមដានកុមារនៅក្នុងគ្រឹះស្ថានដែលផ្តល់សេវាស្នាក់នៅនិងដែលត្រួតពិនិត្យ គ្រប់គ្រង និងធ្វើអធិការកិច្ចលើគ្រឹះស្ថានដែលផ្តល់សេវាស្នាក់នៅ។*

**ចម្លើយ** :

១- ការថែទាំកុមារកំព្រានៅក្នុងស្ថាប័ន និងក្នុងមណ្ឌលស្នាក់នៅត្រូវបានបង្កើតឡើងនិងដំណើរការដោយរដ្ឋឬអង្គការមិនមែនរដ្ឋាភិបាល។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាស្នាក់នៅសម្រាប់កុមារកំព្រា មិនយកចំណេញដែលបង្កើតដោយ :

ក- មានការយល់ព្រមពីក្រសួងមហាផ្ទៃ ចំពោះអង្គការមិនមែនរដ្ឋាភិបាលជាតិ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចំពោះអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ

ខ- មានការយល់ព្រមពីក្រសួង ស.អ.យ ឲ្យធ្វើប្រតិបត្តិការលើការថែទាំជំនួសចំពោះកុមារ។

ក្រសួង ស.អ.យ ទទួលខុសត្រូវក្នុងនាមជាអ្នកអាណាព្យាបាលលើការចិញ្ចឹមទុកដាក់កុមារ។ អង្គការមិនមែនរដ្ឋាភិបាលអាចរួមចំណែកដល់ការចិញ្ចឹមបីបាច់ថែទាំកុមារ ក្នុងនាមជាអ្នកថែទាំតែប៉ុណ្ណោះ។ រីឯការត្រួតពិនិត្យ ការគ្រប់គ្រង និងការធ្វើអធិការកិច្ចលើគ្រឹះស្ថានទាំងនោះជាសមត្ថកិច្ចរបស់ ក្រសួង ស.អ.យ។

ចំនួនមណ្ឌល និងចំនួនកុមារដែលទទួលការថែទាំតាមមណ្ឌល និងតាមសហគមន៍មាន :

| **ឆ្នាំ និង ចំនួនមណ្ឌលសរុប** | **ការថែទាំក្នុងមណ្ឌលមាន ២៤ រាជធានី ខេត្ត** | | | **ការថែទាំតាមសហគមន៍មាន ១៩ រាជធានី ខេត្ត** | | |
|---|---|---|---|---|---|---|
| | ចំនួនសរុប | ប្រុស | ស្រី | ចំនួនសរុប | ប្រុស | ស្រី |
| ឆ្នាំ២០០៨ **២៥៧**មណ្ឌល | ១១ ១១៨ នាក់ | ៦ ៧០៤ នាក់ | ៤ ៣១៤ នាក់ | 0 | 0 | 0 |
| ឆ្នាំ២០០៩ **២៥៧**មណ្ឌល | ១១ ៩៤៩ នាក់ | ៧ ១២៣ នាក់ | ៤ ៨២៦ នាក់ | ៦៩១៨ នាក់ | ៣៥២៤ នាក់ | ៣៣៩៤ នាក់ |
| ឆ្នាំ២០១០ **២៦៩**មណ្ឌល | ១១ ៩៤៥ នាក់ | ៦ ៦៤៣ នាក់ | ៥ ៣០២ នាក់ | ៥០០៤ នាក់ | ២៥១៧ នាក់ | ២៣៥៥ នាក់ |

២- ក្នុងឆ្នាំ២០១០ ក្នុងចំណោមមណ្ឌលសរុបចំនួន ២៦៩មណ្ឌល មានមណ្ឌលចំនួន ២១២ បានចុះអនុស្សរណៈជាមួយក្រសួងស.អ.យ។ មណ្ឌលទាំងអស់ត្រួតពិនិត្យដោយក្រសួង ស.អ.យ រៀងរាល់ 0៣ខែម្តង 0៦ខែម្តង ឬ 0១ខែម្តង ក្នុងករណីចាំបាច់។

***សំណួរទី 0៨ - សូមផ្តល់ជូនគណៈកម្មាធិការនូវព័ត៌មានស្តីពីវិធានការដែលបានប្រកាន់យកដើម្បីអនុវត្តអនុសាសន៍លេខ CRC/C/15/Add.123 ត្រង់កថាខ័ណ្ឌ៤១ ឲ្យធ្វើកំណែទម្រង់ច្បាប់ជាធរមានស្តីពីសុំកូនក្នុងប្រទេស។ សូមបញ្ជាក់ផងដែរថា តើប្រកាសស្តីពីការអនុវត្តច្បាប់សុំកូនអន្តរប្រទេសឆ្នាំ២០០៩ ត្រូវបានអនុម័តរួចហើយឬនៅ ? ។***

**ចម្លើយ** :

១- ក្រមរដ្ឋប្បវេណីត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី0៨ ខែធ្នូ ឆ្នាំ២០០៧។ ជំពូកទី៤ ផ្នែកទី២ គន្លឹទី៧ នៃក្រមនេះបញ្ញត្តិអំពីសុំកូន ដែលមាន0២ប្រភេទគឺ សុំកូនពេញលេញ និងសុំកូនធម្មតា។ បទប្បញ្ញត្តិនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារនឹងត្រូវជំនួសដោយបទប្បញ្ញត្តិពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណីចាប់ពីពេលដែលក្រមនេះត្រូវបានដាក់ឲ្យអនុវត្ត។

២- ច្បាប់ស្តីពីសុំកូនអន្តរប្រទេសត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស/រកម/១២០៩/០២៤ ចុះថ្ងៃទី0៣ ខែធ្នូ ឆ្នាំ២០០៩។ ក្រសួង ស.អ.យ កំពុងសហការជាមួយការិយាល័យអចិន្ត្រៃយ៍នៃអនុសញ្ញាក្រុងឡាអេស្តីពីសុំកូនអន្តរប្រទេស និងអង្គការយូនីសេហ្វ រៀបចំប្រកាសដើម្បីអនុវត្តច្បាប់នេះ ប្រកបដោយតម្លាភាព និងមានគណនេយ្យភាព :

| ល.រ | វិធានបទដ្ឋាន | សំគាល់ |
|---|---|---|
| ១ | ប្រកាសស្តីពីការកែសម្រួលតួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងសមាសភាពរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា | កំពុងពិភាក្សាជាមួយការិយាល័យអចិន្ត្រៃយ៍ក្រុងឡាអេ |
| ២ | ប្រកាសស្តីពីសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស | កំពុងពិភាក្សាជាមួយការិយាល័យអចិន្ត្រៃយ៍ក្រុងឡាអេ |
| ៣ | ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូន អន្តរប្រទេស | កំពុងពិភាក្សាជាមួយការិយាល័យអចិន្ត្រៃយ៍ក្រុងឡាអេ |
| ៤ | ប្រកាសស្តីពីការបែងចែកភារកិច្ចដល់មន្ត្រីរដ្ឋបាលសុំកូនអន្តរប្រទេស | កំពុងពិភាក្សាជាមួយការិយាល័យអចិន្ត្រៃយ៍ក្រុងឡាអេ |
| ៥ | សេចក្តីជូនដំណឹងស្តីពីការធ្វើកិច្ចព្រមព្រៀងទ្វេភាគីដើម្បីកំណត់ចំនួនទីភ្នាក់ងារសុំកូនអន្តរប្រទេស | កំពុងពិភាក្សាជាមួយការិយាល័យអចិន្ត្រៃយ៍ក្រុងឡាអេ |
| ៦ | ប្រកាសស្តីពីនីតិវិធីនៃការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស | សេចក្តីព្រាង |
| ៧ | ប្រកាសស្តីពីការអនុញ្ញាត និងទទួលស្គាល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស | សេចក្តីព្រាង |
| ៨ | កិច្ចសន្យាទីភ្នាក់ងារ | សេចក្តីព្រាង |
| ៩ | អាជ្ញាបណ្ណទីភ្នាក់ងារ | សេចក្តីព្រាង |
| ១០ | ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងប្រាក់ចំណូល ចំណាយ សោហ៊ុយ និងប្រាក់វិភាគទាននានាសម្រាប់ជួយឧបត្ថម្ភដល់ជម្រើសនានានៃការថែទាំជំនួស និងការជួយឧបត្ថម្ភទៅមណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេសនិងកម្រៃសេវាចាំបាច់ផ្សេងទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស | សេចក្តីព្រាង |
| ១១ | ប្រកាសស្តីពីនីតិវិធីនៃការគ្រប់គ្រងកុមារដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស | សេចក្តីព្រាង |
| ១២ | ប្រកាសស្តីពីការអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ | សេចក្តីព្រាង |
| ១៣ | កិច្ចព្រមព្រៀងស្តីពីការកំណត់ចំនួនទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលត្រូវបានអនុញ្ញាតឲ្យផ្តល់សេវាកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា(ភាគីអនុសញ្ញា) | សេចក្តីព្រាង |

*សំណួរទី ០៩ - សូមផ្តល់ជូនគណៈកម្មាធិការនូវព័ត៌មានថ្មីៗស្តីពីវិធានការជាក់ស្តែងនៅក្នុងការអនុវត្តច្បាប់ស្តីពីការបង្ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងការពារជនរងគ្រោះឆ្នាំ២០០៥។ ជាពិសេស សូមបញ្ជាក់ថាតើប្រកាសដែលផ្តល់សមត្ថកិច្ចជូនអាជ្ញាធរឃុំ-សង្កាត់ និងភូមិ នៅក្នុងការការពារជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារត្រូវបានបង្កើតរួចហើយឬនៅ ? ។*

**ចម្លើយ** :

១- វិធានការជាក់ស្តែងនៅក្នុងការអនុវត្តច្បាប់ស្តីពីការបង្ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះរួមមាន :

- ការបណ្តុះបណ្តាលច្បាប់ស្តីពីការបង្ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ជាបន្តបន្ទាប់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងប្រទេស មន្ត្រីនគរបាល យោធា ក្រឡាបញ្ជី ចៅក្រម ព្រះរាជអាជ្ញា និងអាជ្ញាធរដែនដី។
- ការដកស្រង់ខ្លឹមសារចេញពីច្បាប់នេះរៀបចំជាមេរៀនដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សារបស់រាជបណ្ឌិតសភានគរបាលជាតិនិងរាជបណ្ឌិតសភាវិជ្ជាជីវតុលាការ។
- បានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយ ឲ្យមានការយល់ដឹងជាសាធារណៈអំពីបញ្ហា និងកិច្ចការដោះស្រាយអំពើហិង្សាលើស្ត្រី តាមរយៈការបោះពុម្ពឯកសារ ការថតខ្សែវីដេអូអប់រំខ្លីៗ ការធ្វើយុទ្ធនាការ ការផ្សព្វផ្សាយព័ត៌មាន ការផ្តល់សេវាដល់ជនរងគ្រោះនិងរៀបចំវេទិកាសាធារណៈ នៅតាមបណ្តារាជធានី ខេត្ត និងស្រុកមួយចំនួន រួមទាំងការបើកវគ្គផ្សព្វផ្សាយដល់មន្ត្រីរាជការនៅតាមមូលដ្ឋានរាជធានី ខេត្ត ជាបន្តបន្ទាប់ ។

២- ប្រកាសដែលផ្តល់សមត្ថកិច្ចជូនអាជ្ញាធរឃុំ-សង្កាត់ និងភូមិ នៅក្នុងការការពារជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ មិនទាន់បានបញ្ចប់នៅឡើយទេ។ ក្រសួងកិច្ចការនារី និងក្រសួងមហាផ្ទៃកំពុងធ្វើកិច្ចការនេះ។

***សំណួរទី ១០ - សូមផ្តល់ព័ត៌មានលំអិតអំពីសេវាតាមសហគមន៍ដែលមាននៅក្នុងរដ្ឋភាគីសម្រាប់កុមារពិការ និងអំពីការវិភាជន៍ថវិកាសម្រាប់សេវានេះ។ សូមផ្តល់ព័ត៌មានផងដែរអំពីវិធានការដែលបានប្រកាន់យក ដើម្បីអភិវឌ្ឍសេវាសុខភាពផ្លូវចិត្តចំពោះកុមារនៅក្នុងទូទាំងប្រទេស។***

**ចម្លើយ** :

ក្រសួងស.អ.យ សហការជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល សម្រេចបាននូវសមិទ្ធិផលដូចខាងក្រោម :

១- ផ្តល់ការស្តារលទ្ធភាពពលកម្មតាមផ្ទះសម្រាប់កុមារពិការ (Home-based rehadbilitation) តាមរយៈការបង្ហាត់បង្រៀនកុមារឲ្យចេះប្រើប្រាស់ឧបករណ៍សិប្បនិម្មិតនិងរណប ការព្យាបាលដោយចលនា និងការប្រើប្រាស់ឧបករណ៍ងាយៗនៅតាមសហគមន៍ដើម្បីធ្វើជាឧបករណ៍ជំនួយការដើរ និងការបម្លាស់ទីរបស់កុមារពិការ និងចុះត្រួតពិនិត្យតាមដានការប្រើប្រាស់ឧបករណ៍សិប្បនិម្មិតនិងរណប ចុះជួសជុលឧបករណ៍សិប្បនិម្មិត និង រណបនៅតាមសហគមន៍ (Outreach programme) ។ល។

២- ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាពិការភាពតាមសហគមន៍ ក្នុងគោលដៅបំផុសការយល់ដឹងអំពីបញ្ហាពិការភាព ការបង្ការ សិទ្ធិនិងសេចក្តីត្រូវការរបស់ជនពិការ និងកុមារពិការ បំផុសឲ្យមានការចូលរួមពីសហគមន៍ ក្រុមគ្រួសារ អ្នកអាណាព្យាបាល និងមាតាបិតា ក្នុងការយកចិត្តទុកដាក់ជួយដល់ជនពិការ ។

៣- ផ្តល់សេវាពិគ្រោះយោបល់ដល់ក្រុមគ្រួសារ អ្នកអាណាព្យាបាល មាតាបិតា និងកុមារពិការ និងការលើកទឹកចិត្តឲ្យជនពិការ កុមារពិការ មានសេចក្តីសង្ឃឹមក្នុងជីវិត ។

៤- ផ្ដល់សេវាអប់រំតាមផ្ទះ(Home-based Education) និងការបញ្ជូនកុមារពិការឲ្យចូលរៀននៅតាមសាលារៀនរដ្ឋ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ។

៥- ផ្ដល់និងឧបត្ថម្ភសម្ភារៈសិក្សា និងសម្រួលមធ្យោបាយធ្វើដំណើរដល់កុមារពិការក្នុងការសិក្សារៀនសូត្រតាមសហគមន៍ ។

៦- បង្កើតសាលារៀនពិសេសសម្រាប់អប់រំកុមារពិការ និងការបង្កើតឲ្យមានថ្នាក់អប់រំ បញ្ចូលគ្នាសម្រាប់កុមារពិការ និងកុមារមិនពិការ នៅតាមបណ្ដារាជធានី ខេត្ត ក្រុង មួយចំនួន ។

៧- រៀបចំបង្កលក្ខណៈងាយស្រួលចេញចូលសម្រាប់កុមារពិការ នៅតាមសាលារៀននិងទីកន្លែងសាធារណៈមួយចំនួន ដូចជាការរៀបចំឲ្យមានជម្រាល ការបំពាក់ផ្ទាក់ដៃតាមបន្ទប់ទឹក ។ល។

៨- ផ្ដល់អន្តរាគមន៍ទាន់ពេលវេលាដល់ជនពិការនិងកុមារពិការនិងការផ្ដល់សេវាបញ្ជូនជនពិការនិងកុមារពិការ ទៅកាន់សេវាសុខភាពនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ។ល។

៩- លើកកម្ពស់ជីវភាពរស់នៅរបស់ក្រុមគ្រួសារ អ្នកអាណាព្យាបាល មាតាបិតា និងកុមារពិការ តាមរយៈការបណ្ដុះបណ្ដាលមុខជំនាញ ផ្ដួចផ្ដើមមុខរបរខ្នាតតូច និងបំណិនជីវិតនៅតាមសហគមន៍ និងការចងក្រងក្រុមជួយខ្លួនឯង។ល។

១០- ផ្ដល់សេវាសង្គ្រោះបន្ទាន់ដល់ក្រុមគ្រួសារ អ្នកអាណាព្យាបាល មាតាបិតា និងកុមារពិការតាមស្ថានភាពជាក់ស្ដែងដល់ពួកគាត់ជួបប្រទះនៅតាមសហគមន៍ ដូចជា ការជួសជុលផ្ទះ ការផ្ដល់ស្បៀងអាហារ ការផ្ដល់អាហារូបត្ថម្ភ ការផ្ដល់សេវាជួយសង្គ្រោះជនរងគ្រោះដោយសារមីន ។ល។

ទាក់ទងនឹងបញ្ហាថវិកាសម្រាប់ការចំណាយលើសេវាតាមសហគមន៍នេះ ជាទូទៅគឺអាស្រ័យលើថវិកាគម្រោងរបស់អង្គការដៃគូពាក់ព័ន្ធដែលអនុវត្តគម្រោងទាក់ទងនឹងការងារនៅសហគមន៍ ។ ចំពោះថវិការបស់ក្រសួង ស.អ.យ សេវានេះផ្អែកតាមគម្រោងចំណាយជាក់ស្ដែងក្នុងជំពូកថវិការបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត។

ចំនួនអ្នករងគ្រោះដោយសារមីន និងកាកសំណល់ជាតិផ្ទុះពីសង្គ្រាមបានថយចុះពីចំនួន ៤៣២០ ករណី ក្នុងឆ្នាំ១៩៩៦ មកនៅត្រឹម ២៧១ ករណី នាឆ្នាំ២០០៨ ។ គិតត្រឹមដំណាច់ឆ្នាំ២០០៧ជនរងគ្រោះដោយសារគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះបានថយចុះ៦០ភាគរយ បើប្រៀបធៀបនឹងឆ្នាំ២០០៥។ ជនរងគ្រោះដោយសារគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ៧០ភាគរយដែលត្រូវការជំនួយ ទទួលបានការគាំទ្រ ការស្ដារលទ្ធភាពពលកម្ម និងការធ្វើសមាហរណកម្ម។

សេវាសុខភាពផ្លូវចិត្តផ្ដល់ដោយក្រសួង ស.អ.យ ជាពិសេសក្រុមប្រឹក្សាសកម្មភាពជនពិការនិងអង្គការមិនមែនរដ្ឋាភិបាល ដូចជាអង្គការចិត្តសង្គមអន្តរវប្បធម៌(TPO) មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងយុវវ័យ(CCAMH) ជាអាទិ៍។

រាជរដ្ឋាភិបាលនិងក្រសួង ស.អ.យ បានចេញបទដ្ឋានដូចខាងក្រោមទាក់ទងនឹងជនពិការ :

ក- អនុក្រឹត្យលេខ ១១៨ អនក.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ

ខ- អនុក្រឹត្យលេខ ១០៨ អនក.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០ ស្តីពីការកំណត់អត្រានិងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ

គ- ប្រកាសលេខ ០៥៦ ស.អ.យ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ស្តីពីការបង្កើតរដ្ឋបាលសិទ្ធិជនពិការ

ការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ កំពុងត្រូវបានដំណើរការរៀបចំបែបបទដើម្បីស្នើសុំការយល់ព្រមពីរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា។

***សំណួរទី ១១ - សូមផ្តល់ជូនគណៈកម្មាធិការនូវព័ត៌មានថ្មីៗស្តីពីវិធានការជាក់លាក់ដើម្បីឆ្លើយតបទៅនឹងមរណភាពកុមារនិងមាតា កង្វះអាហារូបត្ថម្ភ ការរីករាលដាលនៃមេរោគនិងជំងឺអេដស៍ នៅក្នុងចំណោមកុមារ និងចំនួនកាន់តែកើនឡើងនៃយុវជនដែលញៀនសារធាតុញៀននិងសុរា។***

**ចម្លើយ** :

១- រាជរដ្ឋាភិបាល ជាពិសេសក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍបានប្តេជ្ញាចិត្តខ្ពស់ និងបានវិនិយោគជាច្រើនក្នុងវិស័យសុខាភិបាលដើម្បីឈានទៅសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សលេខ៤ លេខ៥ និងលេខ៦ (ការកាត់បន្ថយមរណភាពកុមារនិងមាតា និងកាត់បន្ថយមេរោគនិងជំងឺអេដស៍និងជំងឺគ្រុនចាញ់ ព្រមទាំងជំងឺឆ្លងផ្សេងៗទៀត)។

មរណភាពកុមារអាយុក្រោម៥ឆ្នាំ បានថយចុះពីចំនួន១២៤នាក់ក្នុងចំនួនកំណើតរស់ ១០០០នាក់ នៅក្នុងឆ្នាំ២០០០ មកនៅ៨៣នាក់ នៅឆ្នាំ២០០៥ និង៥៤ នៅឆ្នាំ២០១០។ អត្រាមរណភាពទារកបានថយចុះពីចំនួន៩៥នាក់នៅក្នុងឆ្នាំ២០០០ មកនៅត្រឹម៦៦នាក់ក្នុងឆ្នាំ២០០៥និង៤៥ នៅឆ្នាំ២០១០។

ស្ថានភាពអាហារូបត្ថម្ភកុមារបានល្អប្រសើរជាងមុន។ អត្រាក្រេះក្រិន(stunted) គឺ៤៣ភាគរយ នៅឆ្នាំ២០០៥ មកនៅ៤០ភាគរយ នៅឆ្នាំ២០១០។ តែអត្រាស្គមស្គាំងខ្លាំង (wasted) មានការកើនឡើងពី ៨ភាគរយ នៅឆ្នាំ ២០០៥ មក ១១ភាគរយ នៅឆ្នាំ២០១០។

ដើម្បីងាយស្រួលនៅក្នុងការសម្របសម្រួលការរៀបចំផែនការ ការរាយការណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃសកម្មភាពសុខភាពមាតានិងកុមារ ក្រុមការងារទី១ដើម្បីសុខភាពមាតា និងកុមារ (Task Force 1 for Maternal and Child Health) មួយត្រូវបានបង្កើតឡើង។ សូចនាករអាទិភាពស្តីពីសុខភាពមាតា និងកុមារចំនួនប្រមាណជា២ភាគ៣បានបង្ហាញឲ្យឃើញថាមាននិន្នាការកើនឡើងនៅក្នុងឆ្នាំ២០១០ បើប្រៀបទៅនឹងឆ្នាំ២០០៩។

២- **សុខភាពបន្តពូជនិងសុខភាពទារក** : ដើម្បីឲ្យមានការងាយស្រួលក្នុងការសម្របសម្រួលអនុក្រុមការងារបច្ចេកទេសខាងផ្នែកសុខភាពមាតានិងកុមារ(Sub Technical Working Group for Maternal

and Child health)មួយ នៅក្នុងមជ្ឈមណ្ឌលគាំពារមាតានិងទារក(NMCH) ដែលមានដៃគូចូលរួមទាំងអស់ចំនួន១៣ មកពីទីភ្នាក់ងារអង្គការសហប្រជាជាតិ ភ្នាក់ងារផ្ដល់ជំនួយអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានបង្កើតឡើង។ មានសកម្មភាពគន្លឹះមួយចំនួន ដែលរួមមានការថែទាំ**ពេលមានគត៌**(ANC) ក្នុងពេល**ប្រសូត្រ** ក្រោយពេលសម្រាលកូន(PNC) ព្រមទាំងការថែទាំទារកផងដែរ។ បុគ្គលិកនៅថ្នាក់ក្រោមជាតិសុទ្ធតែទទួលបាននូវការបណ្ដុះបណ្ដាលអំពីជំនាញសារវ័ន្ត។ កម្មវិធីនេះមានបណ្ដាញតភ្ជាប់គ្នា តាំងពីថ្នាក់ជាតិរហូត ទៅដល់ថ្នាក់ ក្រោមនៅមូលដ្ឋាន គឺមណ្ឌលសុខភាព។ កម្មវិធីបានជ្រៀតចូលទៅដល់ក្នុងសហគមន៍ថែមទៀតផងដែរ។ កម្មវិធីនេះជាអ្នកទទួលខុសត្រូវនៅក្នុងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រថ្នាក់ជាតិ គោលការណ៍និងការណែនាំផ្សេងៗ ការបណ្ដុះបណ្ដាលគ្រូបង្គោល ការរៀបចំផែនការ និងប៉ាន់ប្រមាណអំពីប្រភពធនធានដែលត្រូវការនៅក្នុងកម្មវិធី ការគាំទ្រដល់ថ្នាក់ក្រោមជាតិ ការពិនិត្យតាមដាន និងវាយតម្លៃ និងការត្រួតពិនិត្យ។

ក្នុងឆ្នាំ២០១០ កម្មវិធីនេះបានសម្រេចនូវសមិទ្ធផលគន្លឹះ គឺបានត្រួតពិនិត្យខេត្តចំនួន២០និងមណ្ឌលសុខភាពចំនួន៦៩ ដើម្បីពង្រឹងសកម្មភាពទាក់ទងនឹងសុខភាពបន្តពូជនិងការថែទាំ ទារក។ បុគ្គលិកសុខាភិបាលចំនួន៩០០នាក់ បានទទួលការបណ្ដុះបណ្ដាលជាគ្រូបង្គោលអំពីទិដ្ឋភាពផ្សេងៗនៃការពន្យារកំណើត ការថែទាំក្រោយពេលសម្រាលកូនរួច(PNC) ការថែទាំបន្ទាន់នៅពេលប្រសូត្រនិងចំពោះទារកដែលទើបនឹងកើត (Emergency Obstetric and Newborn Care-EmONC) សៀវភៅស្ដីពីរបៀបប្រើប្រាស់សម្ភារៈបូមទារក (manual of Vaccum Extractor and CBD)។ សកម្មភាពផ្សេងទៀតរួមមានការពិនិត្យមើលឡើងវិញនិងធ្វើបច្ចុប្បន្នភាពសម្ភារៈឧបទ្ទេស និងការបោះពុម្ពបែងចែកផ្សព្វផ្សាយ។

៣- **សុខភាពកុមារ :** គណៈកម្មការជាតិនិងខេត្ត ដើម្បីការរស់រានរបស់កុមារ(National and Provincial Child Survival Management Committee-NCSMC) ត្រូវបានបង្កើតឡើងនៅថ្នាក់ជាតិនិងថ្នាក់ខេត្ត ដោយមានការបញ្ជាក់ច្បាស់លាស់អំពីតួនាទីនិងភារកិច្ច នៅក្នុងការសម្របសម្រួលសកម្មភាពទាក់ទងទៅនឹងសុខភាពមាតានិងកុមារ។ យុទ្ធសាស្ត្រនៃការរស់រានមានជីវិតរបស់កុមារ(Child Survival Strategy) ត្រូវបានបង្កើតឡើងដើម្បីដឹកនាំការធ្វើសកម្មភាពផ្សេងៗ។ ក្រសួងសុខាភិបាលបានអនុម័តយុទ្ធសាស្ត្រសមាហរណកម្មពិនិត្យព្យាបាលជំងឺកុមារ (Integrated Management of Childhood Illness Strategy-IMCI) មួយដែលត្រូវបានរៀបចំសម្របទៅតាមបរិបទរបស់កម្ពុជា។ យុទ្ធសាស្ត្រនេះ មានសមាសភាគ០៣ គឺ១-ធ្វើឲ្យប្រសើរឡើងនូវគុណភាពជំនាញរបស់បុគ្គលិកសុខាភិបាល ២-ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធគាំទ្រសុខភាព និង ៣-ធ្វើឲ្យប្រសើរឡើងនូវការប្រតិបត្តិតាមគ្រួសារនិងសហគមន៍។ យុទ្ធសាស្ត្រនេះត្រូវបានពង្រីកទៅតាមស្ទើរតែគ្រប់មណ្ឌលសុខភាពទាំងអស់ ដោយបើ

ហោចណាស់ឲ្យមានបុគ្គលិកពីរនាក់ដែលបានទទួលការបណ្តុះបណ្តាលអំពីគ្លីនិក(Clinical Trainings)។ នៅក្នុងឆ្នាំ២០១០ សមាមាត្រកុមារដែលបានទទួលវ៉ាក់សាំង DPT-Hep3 និងកញ្ជ្រិល មានលើសពី៩០ភាគរយ។ គុណភាពនៃការថែទាំកុមារនៅតាមមន្ទីរពេទ្យត្រូវបានផ្តល់អាទិភាព។ បុគ្គលិកសុខាភិបាលដែលបម្រើការក្នុងផ្នែកពិគ្រោះអ្នកជំងឺខាងក្រៅ(Outpatient Department) និងនៅតាមអគារថែទាំទារក សុទ្ធតែបានទទួលការបណ្តុះបណ្តាលអំពីរបៀបថែទាំកុមារឈឺ (Pediatric Nursing Care សំរាប់គិលានុប្បដ្ឋាកនិង Essential Pediatric Care សម្រាប់គ្រូពេទ្យ) ដើម្បីឲ្យពួកគេអាចគ្រប់គ្រងជំងឺរបស់កុមារដែលចូលមកសម្រាកព្យាបាលបានល្អ។

៤- **បញ្ហាអាហារូបត្ថម្ភ(Malnutrition)** : ក្នុងមជ្ឈមណ្ឌលគាំពារមាតានិងទារក(MNCHC) មានកម្មវិធីជាតិអាហារូបត្ថម្ភ (National Nutritin Programme - NNP)។ មានដៃគូជាច្រើនដែលគាំទ្រដល់កម្មវិធីអាហារូបត្ថម្ភថ្នាក់ជាតិនេះ តាមរយៈការដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិការប្រចាំឆ្នាំរៀងៗខ្លួន។ មានទឹកប្រាក់ប្រមាណជា២លានដុល្លារ ដែលត្រូវបានប្រគល់ឲ្យសម្រាប់សកម្មភាពឆ្នាំ២០១១នេះ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ។ បញ្ហាអាហារូបត្ថម្ភស្រួចស្រាវ (Acute Malnutrition) គឺជាសកម្មភាពគន្លឹះនៃផែនការជាតិឆ្នាំ២០១០។ កម្មវិធីអាហារូបត្ថម្ភថ្នាក់ជាតិបានសម្រេចបំពេញបាននូវការងារដូចតទៅនេះ:

- រៀបចំអភិវឌ្ឍឡើងនូវគោលការណ៍ណែនាំថ្នាក់ជាតិបណ្តោះអាសន្នមួយ (National Interim Guidelines) និងសម្ភារៈបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបញ្ហាអាហារូបត្ថម្ភស្រួចស្រាវ (Management of Acute Malnutrition) ដែលត្រូវបានយកទៅអនុវត្តសាកល្បងក្នុងខេត្តចំនួនពីរ។
- ការប៉ាន់ប្រមាណគុណភាពនៃការថែទាំ ការពិនិត្យតាមដាន និងត្រួតពិនិត្យសកម្មភាពនៃការគ្រប់គ្រងបញ្ហាអាហារូបត្ថម្ភធ្ងន់ធ្ងររបស់អ្នកជំងឺដែលចូលមកទទួលការព្យាបាល និងការសម្រេចបញ្ចប់លើផ្នែកអ្នកជំងឺដែលចូលមកទទួលការព្យាបាល។
- នៅក្នុងឆ្នាំ២០១០ បុគ្គលិកសុខាភិបាលមកពីមន្ទីរពេទ្យចំនួន០៩ បានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបញ្ហាអាហារូបត្ថម្ភធ្ងន់ធ្ងរ និងបុគ្គលិកសុខាភិបាលមកពីមន្ទីរពេទ្យចំនួន០៥ បានទទួលការបណ្តុះបណ្តាលវិក្រឹត្យការ។
- ក្នុងឆ្នាំ២០១០ កុមារចំនួន១២៧១នាក់បានទទួលការព្យាបាលនៅក្នុងមន្ទីរពេទ្យចំនួន២១ ក្នុងនោះកុមារចំនួន៨៧៧នាក់ត្រូវបានព្យាបាលចប់បញ្ជូនឲ្យត្រលប់ទៅផ្ទះវិញ(discharged) ១៦២នាក់ដែលបោះបង់ការព្យាបាល(dropped out) និង៣០នាក់ត្រូវបានបញ្ជូនទៅកាន់កន្លែងដទៃ។

កម្មវិធីអាហារូបត្ថម្ភថ្នាក់ជាតិក៏មានសកម្មភាពដទៃទៀតដែរ ដែលរួមមានការបង្ការនិងត្រួតពិនិត្យកង្វះឈាមក្រហម ការបង្ការនិងត្រួតពិនិត្យកង្វះជីវជាតិអា ការបង្ការនិងត្រួតពិនិត្យកង្វះជាតិអ៊ីយ៉ូតនិងជំងឺទាក់ទងនឹងកង្វះជាតិអ៊ីយ៉ូដ។

ចំនួនបុគ្គលិកដែលបានទទួលការបណ្ដុះបណ្ដាលស្ដីពីការការគ្រប់គ្រងបញ្ហាអាហារូបត្ថម្ភធ្ងន់ធ្ងរ ២០០៣-២០១០:




## ៥- ការត្រួតពិនិត្យមេរោគ និងជំងឺអេដស៍ (HIV/AIDS Control):

នៅក្នុងក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ (the National Centre for HIV/AIDS, Dermatology, and Sexually Transmitted Diseases-NCHADS) គឺជាអ្នកសម្របសម្រួលសកម្មភាពបង្ការនិងត្រួតពិនិត្យមេរោគនិងជំងឺអេដស៍។ មជ្ឈមណ្ឌលនេះធ្វើការ ជាមួយមជ្ឈមណ្ឌលជាតិកំចាត់ជំងឺរបេងនិងជំងឺហង់សិន(National Centre for Tuberculosis and Leprosis Control) ក្នុងការឆ្លើយតបនឹងមេរោគនិងជំងឺអេដស៍ និងជំងឺរបេង និងជាមួយនឹងមជ្ឈមណ្ឌល ជាតិថែទាំសុខភាពមាតានិងទារក (National Centre for Maternal and Child Health-NMCH) ក្នុង ការឆ្លើយតបរួមគ្នាការពារការចម្លងមេរោគពីម្ដាយទៅកូន "PMTCT" និងសេវាផ្ដល់ប្រឹក្សានិងធ្វើតេស្ដ ឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់"VCCT")។ បច្ចុប្បន្ននេះ នៅមិនទាន់មានការងារបង្ការនិង ត្រួតពិនិត្យមេរោគនិងជំងឺអេដស៍ដាច់ដោយឡែកសម្រាប់កុមារនៅឡើយទេ។

មជ្ឈមណ្ឌលជាតិមានខ្សែបណ្ដោយរបស់ខ្លួនចាប់ពីថ្នាក់ជាតិដល់ថ្នាក់ខេត្តស្រុក មណ្ឌលសុខភាពនិងសហគមន៍នៅក្នុងការអនុវត្តការបង្ការនិងត្រួតពិនិត្យមេរោគនិងជំងឺអេដស៍ ដោយសហការ ជាមួយដៃគូអភិវឌ្ឍន៍។ ផែនការយុទ្ធសាស្រ្តជាតិក្នុងការបង្ការនិងត្រួតពិនិត្យមេរោគនិងជំងឺអេដស៍ ដែលត្រូវបានរៀបចំឡើងសម្រាប់រយៈពេលពីឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១៥ មានគោលដៅសំខាន់០២ គឺទី១ កាត់បន្ថយប្រេវ៉ាឡង់មេរោគអេដស៍ពី 0.៩ ភាគរយ មកត្រឹម 0.៦ ភាគរយ និងទី២ អ្នក ជំងឺអេដស៍អាចរស់រានមានជីវិតលើសពី ៨៥ ភាគរយ។

ការខិតខំប្រឹងប្រែងនិងការវិនិយោគនៅក្នុងការបង្ការនិងត្រួតពិនិត្យមេរោគ និងជំងឺអេដស៍បាន សម្រេចបាននូវសមិទ្ធិផលយ៉ាងធំធេង។ សមិទ្ធិផលមួយគឺការកាត់បន្ថយប្រេវ៉ាឡង់មេរោគអេដស៍ នៅក្នុងចំណោមប្រជាជន ជាក់ស្តែង គឺប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនដែលមានអាយុ ពី ១៥ ដល់ ៤៩ ឆ្នាំបានថយចុះជាបន្តបន្ទាប់ ពី ២ ភាគរយ នៅក្នុងឆ្នាំ១៩៩៨ មកត្រឹម ០.៩ ភាគរយ នៅក្នុងឆ្នាំ២០០៦ និងបន្ទាប់មកមកត្រឹម ០.៧ ភាគរយ នៅក្នុងឆ្នាំ២០១០។

អគារសុខាភិបាលដែលមានសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់"VCCT" បានកើនឡើងពីចំនួន១២នៅក្នុងឆ្នាំ២០០០ មក២៣៩នៅក្នុងឆ្នាំ២០១០ (ត្រីមាសទី៣)។ រហូតមកដល់ត្រីមាសទី៣នៃឆ្នាំ២០១០ មានប្រជាជនចំនួន ៣៨៧ ៥៧៥នាក់ ដែលបានមកទទួលយកសេវានេះ ក្នុងនោះមាន VCCT ៦៨ ភាគរយ អ្នកជំងឺរបេង ៤ ភាគរយ នារីមានផ្ទៃពោះ២៩ ភាគរយ និងដៃគូនារី ៦ ភាគរយ។

CENATនិងNCHADS បានអភិវឌ្ឍឡើងនូវក្របខ័ណ្ឌជាតិសម្រាប់ជំងឺរបេងនិងជំងឺអេដស៍។នៅក្នុងឆ្នាំ២០១០ មានស្រុកប្រតិបត្តិចំនួន២៥ នៅក្នុងខេត្តចំនួន ១២ ដែលបានអនុវត្តការគ្រប់គ្រង ការបង្ករោគរួមគ្នាដោយមេរោគរបេងនិងមេរោគអេដស៍(management of TB-HIV co-infection)។

ការព្យាបាលជំងឺឱកាសនិយម (opportunistic infections-OIs)លើអ្នកជំងឺអេដស៍ ដោយ Antiretrovirals-ARVs គឺជាអាទិភាពចម្បងមួយរបស់ NCHADS។ នៅក្នុងឆ្នាំ២០១០ មានស្រុកប្រតិបត្តិចំនួន៥១នៅក្នុងខេត្តចំនួន២១ ដែលមានសមត្ថភាពអាចធ្វើការគ្រប់គ្រងលើអ្នកជំងឺអេដស៍ដែលមានជំងឺឱកាសនិយមបាន ហើយបានផ្តល់ថ្នាំ ARVs ឲ្យ។ មានស្រុកប្រតិបត្តិ ៣២ ក្នុងចំណោមស្រុកប្រតិបត្តិទាំងនោះ ដែលត្រូវបានលើកកម្ពស់ឲ្យអាចផ្តល់ការថែទាំដល់កុមារ ដែលមាន HIV/AIDS បាន។ រហូតមកដល់ត្រីមាសទី៣នៃឆ្នាំ២០១១ មានអ្នកជំងឺអេដស៍សរុបចំនួន៤១៦៦៩នាក់ ដែលបានទទួលថ្នាំ ARVs ក្នុងនោះប្រមានជា ១០ភាគរយ ជាកុមារ។

ក្នុងខេត្តចំនួន២១ មានអ្នកមកធ្វើតេស្ត VCCT ចំនួន ២៦២ ៤២១ នាក់ អ្នកជំងឺរបេង ១៥ ០៥២ នាក់ អ្នកទទួលសេវាពិនិត្យ ព្យាបាលជំងឺអេដស៍ARVs ចំនួន៤១៦៦៩ នាក់ ក្នុងនោះ ៤០០៣ ជាកុមារ។ មានគ្រូពេទ្យច្រើនជាង១០០នាក់ ដែលបានទទួលការបណ្តុះបណ្តាលនៅក្នុងកម្មវិធីបណ្តុះបណ្តាលរយៈពេល៦ខែ ដែលមានឈ្មោះថាសញ្ញាប័ត្រគ្រប់គ្រងគ្លីនិកមេរោគ និងជំងឺអេដស៍សម្រាប់ កុមារ (diploma in clinical management training course on HIV/AIDS for children) និងមេរៀន សម្របសម្រួលខ្លីៗជាច្រើនទៀត។

រហូតមកដល់ខែធ្នូឆ្នាំ២០១០ មានអគារសុខាភិបាលសរុបចំនួន៩២១ ដែលបានអនុវត្តកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (Prevention of Mother to Child Transmission program - PMTCT) ក្នុងនោះមានមន្ទីរពេទ្យជាតិចំនួន៣ មន្ទីរពេទ្យបង្អែកចំនួន៧៤ មណ្ឌលសុខភាព ចំនួន ៨៤ និងអគារសុខាភិបាលរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន ១៧ ។ អគារសុខាភិបាលដែលអនុវត្តកម្មវិធីបង្ការនេះ មានយ៉ាងតិចអ្នកថែទាំសុខភាពចំនួន២នាក់មកពីមណ្ឌលសុខភាព និងមានគ្រូពេទ្យម្នាក់ដែលបានទទួលការបណ្តុះបណ្តាលស្តីពីការពិគ្រោះយោបល់អេដស៍មុន និងក្រោយការធ្វើតេស្ត។ អ្នកគ្រប់គ្រងមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ និងគ្រប់កម្រិតនៃការគ្រប់គ្រងនៅថ្នាក់ខេត្ត សុទ្ធតែបានទទួលការបណ្តុះបណ្តាលអំពីការគ្រប់គ្រងការបង្ការការចម្លងរោគពីមាតាទៅទារក។

សូចនាករសុខភាពមាតានិងកុមារ :

| សូចនាករ<br>Indicators | សមិទ្ធិផល<br>Achievements | | គោលដៅ<br>Target |
|---|---|---|---|
| | 2009 | 2010 | |
| **សុខភាពបន្តពូជ** Reproductive Health | | | |
| ប្រេវ៉ាឡង់នៃការប្រើគ្រឿងបង្ការមិនឲ្យមានកូនបែប ទំនើប | 28% | 30% | 40% |
| ចំនួនអគារសុខាភិបាលដែលផ្តល់សេវាដល់តរុណវ័យនិងយុវជន (Adolescents Youth Friendly Services (**AYFS**) | 110 | 226 | 135 |
| **មាតានិងទារក** Maternal and Newborn | | | |
| % នារីមានគភ៌ដែលមកឲ្យបុគ្គលិកសុខាភិបាលពិនិត្យ ផ្ទៃពោះ | 83% | 72% | 85% |
| % ការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានការបណ្តុះបណ្តាល នៅអគារសុខាភិបាល | 44% | 52.31% | 50% |
| % កំណើតដោយបុគ្គលិកសុខាភិបាលដែលមានការបណ្តុះបណ្តាល | 63% | 62.21% | 70% |
| % ការសម្រាលកូនដោយ C-section | 1.4% | 2% | 2.5% |
| % នារីមានគភ៌ដែលមានផ្ទុកមេរោគអេដស៍ ដែលបានទទួល ART ដើម្បីបង្ការការចម្លងរោគពីមាតាទៅទារក PMTCT | 32.3% | 57.3% | 50% |
| % នារីមានគភ៌ដែលមកពិនិត្យផ្ទៃពោះ ហើយធ្វើតេស្តអេដស៍ | 70.9% | 81.1% | 80% |
| **អាហារូបត្ថម្ភ** Nutrition | | | |
| % នារីមានគភ៌ដែលបានទទួលគ្រាប់ថ្នាំជាតិដែក | 83% | 80% | 83% |
| % នារីសម្រាលកូនរួចហើយដែលបានទទួលគ្រាប់ថ្នាំជាតិដែក | 68% | 73% | 75% |
| % នារីដែលសម្រាលកូនរួចហើយបានទទួលវីតាមីនអាក្នុងអំឡុងពេល៦សប្តាហ៍ | 71% | 73% | 75% |
| % កុមារអាយុ6-59 ខែដែលបានទទួលវីតាមីនអា២ដូស ក្នុងពេល៦ខែកន្លងមក | R1: 98%<br>R2: 100 | R1:95%<br>R2:96% | R1:98%<br>R2:98% |

| | | | |
|---|---|---|---|
| % កុមារអាយុ12-59 ខែដែលបានទទួល mebendazole រាល់ពេល៦ខែម្តង | 86% | 92% | 88% |
| ចំនួនមន្ទីរពេទ្យបង្អែកដែលមាន CEmONC | 25 | 25 | 26 |
| ចំនួនមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាពដែលមាន BEmONC | 19 | 19 | 34 |
| **សុខភាពកុមារ** Child Health | | | |
| % កុមារអាយុក្រោម១ឆ្នាំដែលបានទទួលថ្នាំបង្ការ DPT3-HepB | 95% | 92% | 96% |
| % កុមារអាយុក្រោម១ឆ្នាំដែលបានទទួលថ្នាំបង្ការជំងឺកញ្រ្ជឹល | 91% | 93% | 95% |
| ចំនួនពិនិត្យជំងឺក្នុង១ឆ្នាំ ចំពោះកុមារអាយុក្រោម៥ឆ្នាំ (new cases consultations ) | 1.0 | 1.51 | 1.3 |
| % មណ្ឌលសុខភាពដែលអនុវត្ត IMCI [IMCI-CS] | 78%* | 100 %* | 80% |

៦- **យុវជនដែលញៀនសារធាតុញៀននិងសុរា:**

**ក-** ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ក្នុងគោលបំណងអភិវឌ្ឍយុវជនឲ្យមានបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា ស្មារតី សីលធម៌ តម្លៃ និងបំណិន ដើម្បីឲ្យយុវជនក្លាយជាពលរដ្ឋល្អក្នុងសង្គមជាតិ។ គោលនយោបាយនេះ ត្រូវបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសុំការអនុម័ត។

**ខ-** រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ សេចក្តីព្រាងច្បាប់ថ្មីស្តីពីការត្រួតពិនិត្យគ្រឿងញៀនបានដាក់បញ្ចូលបទប្បញ្ញត្តិទាក់ទងនឹងវិធានការព្យាបាលនិងស្តារនីតិសម្បទា។ សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់ ក៏កំពុងស្ថិតនៅក្នុងដំណើរការពិនិត្យឡើងវិញដែរ ។

**គ-** រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ : ១៦២.អនក្រ.បក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ មជ្ឈមណ្ឌលនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស.អ.យ។

**ឃ-** ដោយមានការគាំទ្រពី CCJAP និង UNODC ក្រសួងមហាផ្ទៃ និងអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀនបានអនុវត្តនូវកម្មវិធីដូចខាងក្រោមនេះ :

- កម្មវិធីបង្ការបទឧក្រិដ្ឋ និង សុវត្ថិភាពសហគមន៍ និង
- ការផ្តួចផ្តើមឡើងនូវការព្យាបាលការញៀនសារធាតុញៀនដោយស្ម័គ្រចិត្តនៅសហគមន៍ ការស្តារសម្បទា និងសេវាជំនួស។

***សំណួរទី ១២ - សូមផ្តល់ព័ត៌មានស្តីអំពីវិធានការកាត់បន្ថយភាពក្រីក្រដែលមាននៅក្នុងរដ្ឋភាគី និងជាពិសេសអំពីការរៀបចំនូវបណ្តាញសុវត្ថិភាពសង្គម សម្រាប់ក្រុមជនដែលមានការខ្វះខាតខ្លាំងជាងគេនិងក្រុមគ្រួសារដែលមិនសូវត្រូវបានគេរាប់រក។***

**ចម្លើយ** :

១- ការកាត់បន្ថយភាពក្រីក្រគឺជាគោលដៅខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយនេះគឺជាបញ្ហាអន្តរវិស័យ ដែលពុំមានស្ថាប័នណាមួយអាចទទួលខុសត្រូវបានដោយឯកឯងបានឡើយ។ គ្រប់អង្គការស្ថាប័ន ទាំងស្ថាប័នរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលចូលរួម ចំណែកក្នុងការកាត់បន្ថយភាពក្រីក្រតាមតួនាទីរៀងៗខ្លួន។ ដោយឡែកក្រសួងផែនការជាសេនាធិការរបស់រាជរដ្ឋាភិបាល មានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យភាពក្រីក្រក្នុងកំរិតទូទាំងប្រទេស។ ឆ្លើយតបទៅនឹងតួនាទីនេះ ក្រសួងផែនការសហការជាមួយអង្គការអន្តរជាតិនានា ធ្វើការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចទ្រង់ទ្រាយធំ រៀងរាល់៣-៤ ឆ្នាំម្តង ហើយតាមរយៈការវិភាគទៅលើលទ្ធផលនៃការអង្កេតសេដកិច្ច-សង្គមកិច្ច បានបង្ហាញឱ្យឃើញថា ភាគរយនៃប្រជាជនកម្ពុជា ដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្របានធ្លាក់ចុះជា លំដាប់ពី៣៦ ភាគរយ នៅឆ្នាំ១៩៩៩ មក ៣៤.៧ ភាគរយ នៅឆ្នាំ ២០០៤ និងធ្លាក់ចុះមក ៣០ ភាគរយ នៅឆ្នាំ២០០៧ (តាមទិន្នន័យរបស់ក្រសួងផែនការ) បន្ទាប់មកទៀតធ្លាក់ដល់ ២៥.៨ ភាគរយ នៅឆ្នាំ២០១០ (យោងតាមយុទ្ធសាស្រ្តជាតិគាំពារសង្គម សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះឆ្នាំ២០១១)។ ជាមួយគ្នានេះដែរ ក្រសួងផែនការអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅកម្ពុជា នោះជាគឺការរកឱ្យឃើញគ្រួសារក្រីក្រពិតប្រាកនៅតំបន់ជនបទ ក្នុងគោលបំណងផ្តល់ទិន្នន័យគ្រួសារក្រីក្រ ឱ្យបានទូលំទូលាយដល់អ្នកភ្នាក់ងារអភិវឌ្ឍ និងអ្នកផ្តល់ជំនួយនិងសេវាទាំងឡាយទាំងស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ជាពិសេសម្មវិធីទាំងឡាយដែលមានលក្ខណៈស្ថិតនៅក្នុងប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីស្ថាប័នទាំងនោះ តំរង់ទិសការផ្តល់ជំនួយនិងសេវាឱ្យចំទិសដៅដល់គ្រួសារក្រីក្រពិតប្រាក ដើម្បីជួយពួកគេឱ្យងើបផុតពីភាពក្រីក្រ និងការពារពួកគេពីវិបត្តិផ្សេងៗ ដូចជាជំងឺធ្ងន់ធ្ងរ ខូចខាតផលដំណាំ ។ល។ ដែលអាចធ្វើឱ្យភាពក្រីក្ររបស់ពួកគេធ្លាក់ចុះកាន់តែធ្ងន់ធ្ងរ។ ទិន្នន័យនេះ ក៏អាចប្រើប្រាស់ផងដែរ ដើម្បីគណនា អត្រាប្រៀបធៀបកំរិតភាពក្រីក្រ កម្រិតខេត្ត កម្រិតស្រុក/ខណ្ឌ កម្រិតឃុំ/សង្កាត់ និងកំរិតភូមិ ដើម្បីកំណត់តំបន់អាទិភាពសម្រាប់ធ្វើការអភិវឌ្ឍន៍ និងការផ្តល់ជំនួយនិងសេវា តាមរយៈ នេះ អ្នកក្រីក្រក៏អាចទទួលបានផលប្រយោជន៍ពីតំបន់អភិវឌ្ឍន៍ទាំងនោះ។ កម្មវិធីអត្តសញ្ញាណកម្ម គ្រួសារក្រីក្របាននិងកំពុងពង្រីកវិសាលភាពនៃការគ្របដណ្តប់ ក្នុងកម្រិតទូទាំងប្រទេសក្នុងឆ្នាំ ២០១០-២០១១។ ទិន្នន័យគ្រួសារក្រីក្របាននិងកំពុងស្វាគមន៍ និងប្រើប្រាស់ដោយស្ថាប័នជាច្រើន ទាំងស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារអភិវឌ្ឍ ក្នុងការតម្រង់ទិសការផ្តល់ជំនួយនិងសេវាដល់ជនក្រីក្រ។ ស្ថាប័ននាំមុខនៅក្នុងរាជរដ្ឋាភិបាលដែលបានប្រើប្រាស់បញ្ជីគ្រួសារក្រីក្រនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រគឺមូលនិធិសមធម៌របស់ក្រសួងសុខាភិបាល ដែលកំពុង

ឈានមុខគេក្នុងការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ សម្រាប់ការផ្តល់សេវាព្យាបាលសុខភាពដល់គ្រួសារក្រីក្រដោយមិនគិតថ្លៃឬបញ្ចុះតម្លៃនៅគ្រប់តំបន់ដែលគ្រប់ដណ្តប់ដោយកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ក្រៅពីនេះ ក៏មានក្រសួង-ស្ថាប័ន អង្គការ តាមវិស័យដ៏ទៃទៀត រួមមានផ្នែកសង្គមកិច្ច អប់រំ កសិកម្ម អភិវឌ្ឍន៍ជនបទ កាកបាទក្រហមនិងអង្គការនានាកំពុងប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រសម្រាប់សកម្មភាពផ្សេងៗ ដូចជា: ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ការផ្តល់ជីពូជស្រូវ ឧបករណ៍ និងបច្ចេក ទេសកសិកម្ម ធុងទឹកចម្រោះ បង្គន់អនាម័យ កង់សម្រាប់សិស្សក្រីក្រ ផ្តល់អង្ករពលកម្ម សេវាសុខភាព និងស្ថាប័នឯកជនផងដែរ។ល។ ទិន្នន័យគ្រួសារក្រីក្រ ជាឧបករណ៍ដ៏សំខាន់បំរើឱ្យប្រព័ន្ធសុវត្ថិភាពសង្គម។

## ២- ការរៀបចំបណ្តាញប្រព័ន្ធសុវត្ថិភាពសង្គម

នៅក្នុងកិច្ចប្រជុំវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី០២ កាលពីថ្ងៃទី៣-៤ ខែធ្នូ ឆ្នាំ ២០០៨ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍបានព្រមព្រៀងពិនិត្យឡើងវិញនូវវិសាលភាពនៃប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គម ក្នុងការទប់ទល់នឹងហានិភ័យនៃអស្ថិរភាពតម្លៃអាហារនិងកលិយុគ សេដ្ឋកិច្ចដែលប៉ះពាល់ទៅលើជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ និងជនដែលងាយរងគ្រោះ។ ជំហានដំបូងនៃការងារនេះ គឺការរៀបចំឡើងនូវកិច្ចការវិភាគទូទៅក្នុងការកំណត់នូវវិសាលភាពនៃប្រព័ន្ធសុវត្ថិភាពសង្គមដែលមានស្រាប់ (បណ្តាកម្មវិធីនានាដែលមានលក្ខណៈជាកម្មវិធីស្ថិតនៅក្រោមប្រព័ន្ធសុវត្ថិភាពសង្គម) និងការកំណត់ទិសដៅនិងជម្រើសយុទ្ធសាស្ត្រ សម្រាប់បង្កើតប្រព័ន្ធសុវត្ថិភាពសង្គមមួយដែលមានលក្ខណៈចម្រោះនិងជាប្រព័ន្ធនិងស្របតាមស្ថានភាពសង្គម-សេដ្ឋកិច្ច នៅកម្ពុជា។ ការរៀបចំយុទ្ធសាស្ត្រនេះធ្វើឡើងដោយក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទនៃគណៈរដ្ឋមន្ត្រី សហការជាមួយបណ្តាក្រសួង ស្ថាប័នដែលពាក់ព័ន្ធ រួមជាមួយអង្គការអន្តរជាតិនានា។ យុទ្ធសាស្ត្រនេះបានប្រមូលចងក្រងលើកឡើងនូវសកម្មភាពជាអទិភាពក្នុងបណ្តាកម្មវិធីនានា ដែលមានស្រាប់ និងមានលក្ខណៈជាកម្មវិធីជួយដល់ប្រព័ន្ធសុវត្ថិភាពសង្គមនិងធ្វើការប៉ាន់ស្មានថវិកាសម្រាប់ការអនុវត្តសម្រាប់ឆ្នាំ២០១០-២០១៣ ក្នុងនោះសារសំខាន់នៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្របានលើកឡើង និងការប៉ាន់ស្មានថវិកាសម្រាប់ការអនុវត្តត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ។ យុទ្ធសាស្ត្រនេះ ត្រូវបានអនុម័តនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១។

*យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ មានគោលដៅចម្បង ០៥ រួមមាន :*

ក- ជនក្រីក្រនិងជនងាយរងគ្រោះទទួលបានការគាំទ្រ រួមមានស្បៀង អនាម័យ ទឹកស្អាត និងជម្រក ។ល។ ដើម្បីបំពេញតាមតម្រូវការរបស់ពួកគាត់ក្នុងពេលវេលាមានគ្រោះអាសន្ននិងហានិភ័យ នានា។

ខ- ជនក្រីក្រ កុមារ និងមាតាងាយរងគ្រោះទទួលបានផលប្រយោជន៍ពីប្រព័ន្ធសុវត្ថិភាពសង្គមដើម្បីកាត់បន្ថយភាពក្រីក្រនិងអសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការបង្កើនគុណភាពអាហារូបត្ថម្ភ សុខមាលភាពមាតានិងកុមារ ការលើកកម្ពស់វិស័យអប់រំ និងការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរ។

គ- ជនក្រីក្រនិងជនងាយរងគ្រោះពេញវ័យធ្វើការងារទទួលបានផលប្រយោជន៍ ពីកលានុវត្តភាពការងារ ដើម្បីធានាអោយមានប្រាក់ចំណូល ស្បៀងនិងមានការងារធ្វើព្រមទាំងចូលរួមក្នុងការកសាងធនធានរូបវន្តនិងធនធានហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមាននិរន្តរភាព។

ឃ- ជនក្រីក្រនិងជនងាយរងគ្រោះទទួលបានការថែរក្សាសុខភាពដែលមានគុណភាព និងអាចទទួលយកប្រើប្រាស់បាន និងការគាំពារផ្នែកហិរញ្ញវត្ថុពេលមានជំងឺ។

ង- ក្រុមជនងាយរងគ្រោះ ជាពិសេសក្មេងកំព្រា ចាស់ជរា ស្ត្រីជាមេគ្រួសារ ជនពិការ អ្នកផ្ទុកមេរោគអេដស៍ឬអ្នកជំងឺរបេង។ល។ទទួលបានការគាំទ្រ ជាប្រាក់ចំណូល សម្ភារៈ និងចិត្តសាស្ត្រសង្គម ព្រមទាំងការថែទាំសង្គមគ្រប់គ្រាន់។

៣- ក្រសួង ស.អ.យ បានចេញសារាចរណែនាំលេខ០០៦ ស.អ.យ ស្តីពីកម្មវិធីជំនួយសង្គ្រោះប្រជាជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងមហន្តរាយជាយថាហេតុ។ សារាចរនេះត្រូវបានរៀបចំកែសម្រួលឲ្យទៅ "អនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការនិងជនក្រីក្រងាយរងគ្រោះនៅតាមសហគមន៍"។ អនុក្រឹត្យនេះត្រូវបានបញ្ជូនទៅគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យនិងសម្រេច។

៤- ចំពោះសមិទ្ធផលផ្សេងៗទៀតទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ សូមមើលឧបសម្ព័ន្ធទី០២ នៃរបាយការណ៍។

*សំណួរទី ១៣ - សូមផ្តល់ព័ត៌មានលំអិតអំពីការបណ្តេញក្រុមគ្រួសារ និងកូនៗរបស់ពួកគេចេញពីដីធ្លីដែលកើតមានតាំងពីឆ្នាំ២០០០មក អំពីស្ថានភាពនៃការរស់នៅរបស់ពួកគេនៅលើទីតាំងថ្មី និងអំពីវិធានការដែលបានប្រកាន់យកនៅក្នុងការធានាសិទ្ធិកាន់កាប់ដីធ្លី។ សូមផ្តល់ព័ត៌មានឲ្យបានច្បាស់លាស់ផងដែរអំពីសមាមាត្រក្រុមគ្រួសារតាមជនបទដែលគ្មានដីធ្លី។ តើរដ្ឋភាគីមានបានធ្វើការប៉ាន់ប្រមាណអំពីផលប៉ះពាល់នៃអស្ថេរភាពនៃសិទ្ធិកាន់កាប់ដីធ្លីទៅលើសមត្ថភាពរបស់គ្រួសារនៅក្នុងការចិញ្ចឹមបីបាច់ថែរក្សាបុត្រធិតាដែរឬទេ?*

**ចម្លើយ** :

១- សិទ្ធិលើកម្មសិទ្ធិត្រូវបានទទួលការគាំពារពីរដ្ឋធម្មនុញ្ញ។ របបកម្មសិទ្ធិលើអចលនវត្ថុត្រូវបានធានាការពារដោយច្បាប់ភូមិបាល ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។ មាត្រា៥នៃច្បាប់ភូមិបាលបញ្ញត្តិថា " គ្មានបុគ្គលណាមួយត្រូវបានគេដកហូត កម្មសិទ្ធិបានទេ ប្រសិនបើការដកហូតនោះមិនមែនដើម្បីប្រយោជន៍សាធារណៈ។

ការដកហូតត្រូវទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់និងបទបញ្ជា បន្ទាប់ពីបានផ្តល់សំណង ជាមុនដោយសមរម្យនិងយុត្តិធម៌។″

២- ច្បាប់ស្តីពីអស្សាមិករណ៍ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០។ បន្ថែមលើការធានាការពារដោយរដ្ឋធម្មនុញ្ញនិងច្បាប់ភូមិបាល ច្បាប់ស្តីពីអស្សាមិករណ៍ កំណត់នូវគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និងសំណងឲ្យបានសមរម្យនិងយុត្តិធម៌ ក្នុងករណីមានការដកហូតកម្មសិទ្ធិ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។ ក្រៅពីច្បាប់ខាងលើមានបទបញ្ញាជាច្រើនទៀតគ្របដណ្តប់កម្មសិទ្ធិដីធ្លីត្រូវបានអនុម័តសំដៅគ្រប់គ្រង រៀបចំប្រើប្រាស់ និងបែងចែកដី ក៏ដូចជាបង្កើតយន្តការ និងនីតិវិធីដោះស្រាយវិវាទនិងត្រួតពិនិត្យតាមដាន ការរំលោភបំពានកម្មសិទ្ធិ។

៣- គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាគឺធានាថាដីទាំងអស់ត្រូវបានគ្រប់គ្រង រៀបចំប្រើប្រាស់ និងបែងចែក ប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងចីរភាព។ នៅក្នុងផ្ទៃដីសរុបប្រមាណ ១៨,១ លានហិកតា ផ្ទៃដីដែលគ្រប់គ្រងដោយរដ្ឋមានប្រមាណ ១៤,៥លានហិកតា និងគ្រប់គ្រងដោយឯកជនមានប្រមាណ ៣,៦លានហិកតា (ស្មើនឹង ២០ភាគរយ) ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់លើការពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ទាំងដីរដ្ឋ ដីឯកជននិងដីសហគមន៍ជនជាតិដើមភាគតិច តាមរយៈការចុះបញ្ជីដីធ្លីជាប្រព័ន្ធនិងដាច់ដោយដុំដើម្បីផ្តល់បណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋទូទៅស្ថាប័ននិងសហគមន៍ជនជាតិដើមភាគតិចដែលមានសិទ្ធិកាន់កាប់ ។

៤- គិតត្រឹមឆ្នាំ២០១០ ប័ណ្ណចំនួន ១ ៦៦៤ ២៩៧ ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋ ក្នុងនោះមាន ៣/៤ ជាដីនៅតំបន់ជនបទ និង ១/៤ ជាដីតំបន់ទីក្រុង ទីប្រជុំជន ហើយ បណ្ណកម្មសិទ្ធិដីធ្លីចំនួន ១ ០៧០ ៦៦៥ ត្រូវបានផ្តល់តាមរយៈការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ និង៥៩៣ ៦៤៥ បណ្ណ តាមរយៈការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ពោលគឺ ប្រមាណ ២៣ភាគរយ ទៅ ២៤ភាគរយ នៃចំនួនក្បាលដីឯកជន សរុបទូទាំងប្រទេសត្រូវបានចុះបញ្ជី។ ចំពោះការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិ សមូហភាពរបស់សហគមន៍ នៅក្នុងតំបន់អនុវត្តសាកល្បងចំនួន០៣សហគមន៍ ការធ្វើអត្តសញ្ញាណកម្មដី និងការកំណត់ព្រំប្រទល់ដី ត្រូវបានបញ្ចប់ដោយបានធ្វើការពិគ្រោះយោបល់ពីបញ្ហាព្រំប្រទល់ដី ជាមួយអ្នកពាក់ព័ន្ធនានា។ ការងារក្នុងជំហានបន្ទាប់គឺការបន្តអនុវត្តអនុក្រឹត្យលេខ ៨៣ អនក្រ.បក ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ ជនជាតិដើមភាគតិចសម្រាប់សហគមន៍ដែលមានការទទួលស្គាល់ជាផ្លូវការរួចហើយក្នុងក្របខណ្ឌទូទាំងប្រទេស ជាពិសេសសហគមន៍ជនជាតិដើមភាគតិច នៅខេត្តមណ្ឌលគិរីនិងខេត្តរតនៈគិរី ។

៥- គណៈកម្មការសុរិយោដី មានបេសកកម្មដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសុរិយោដី។ វិវាទទាក់ទងនឹងអចលនវត្ថុដែលមានចុះបញ្ជីសុរិយោដីដោះស្រាយដោយ

តុលាការ។ ចំនួនករណីវិវាទដែលត្រូវបានបញ្ជូនមកគណៈកម្មាធិការសុរិយោដី បានថយចុះពីមួយឆ្នាំទៅមួយឆ្នាំ ប្រមាណ ២០ ភាគរយ ហើយការដោះស្រាយ មានការកើនឡើងជិត ៥៦ ភាគរយ ។ តាមរយៈនីតិវិធីដោះស្រាយវិវាទចល័ត សំណុំរឿងវិវាទដីធ្លីដែលកកស្ទះជាច្រើនត្រូវបានដោះស្រាយបញ្ចប់ទាំងស្រុង ។

គិតត្រឹមឆ្នាំ២០១០ ក្នុងការងារដោះស្រាយវិវាទដីធ្លី ដែលមានចំនួនសរុប ៥ ១៩៣ករណី គណៈកម្មាធិការ សុរិយោដី គ្រប់ថ្នាក់ បានសម្រេចលទ្ធផលការងារ ដូចខាងក្រោម៖

- វិវាទចំនួន ១ ៨១០ ករណី ពាក់ព័ន្ធនឹង៨ ៥៦០ គ្រួសារ និង ផ្ទៃដីទំហំ៣ ០៥៧,២ហិកតា ត្រូវបានដោះស្រាយជាស្ថាពរ
- សំណុំរឿងដែលបានដកពាក្យបណ្តឹងវិញមានចំនួន២៧២ករណី
- វិវាទចំនួន១ ៣៦៩ ករណី មិនត្រូវបានទទួលយកមកដោះស្រាយទេ ដោយសារមិនស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួន
- វិវាទចំនួន ១ ៧៤២ ករណី ត្រូវបានព្យួរទុកមិនទាន់ដោះស្រាយ។

៦- ដើម្បីពង្រឹងការរៀបចំដែនដី ណើរការកសាងក្របខ័ណ្ឌគោលនយោបាយនិងក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យនេះ ដូចជាគោលនយោបាយរៀបចំដែនដី គោលនយោបាយជាតិស្តីពីលំនៅឋាន សារាចរណែនាំស្តីពីនីតិវិធីដោះស្រាយសំណង់បណ្តោះអាសន្នក្នុងទីក្រុងឬទីប្រជុំជននិងច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងតែប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌនៃក្រុម ការងារអន្តរក្រសួង ។

៧. រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តគោលនយោបាយបែងចែកដីដល់ប្រជាជនក្រីក្រ និងគ្រួសារកងកម្លាំងប្រដាប់អាវុធកំពុងឈរជើងការពារទឹកដីនៅភាគខាងលិចនិងពាយ័ព្យនៃប្រទេស ដែលគ្មានដីនិងខ្វះដី តាមរយៈកម្មវិធីផ្តល់សម្បទានដីសង្គមកិច្ច ដែលផ្តួចផ្តើមដោយថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ* និង *យុទ្ធសាស្ត្រអភិវឌ្ឍតាមវិស័យ* (ផយអជ) ២០០៦-២០១០ បានកំណត់ផ្តល់ដីដល់គ្រួសារប្រជាពលរដ្ឋក្រីក្រ ដែលគ្មានដីចំនួន ១០ ០០០ គ្រួសារ នៅក្រោមកម្មវិធីនេះ។ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវសារាចរណែនាំស្តីពីផែនការបែងចែកសម្បទានដីសង្គមកិច្ច ដោយតម្រូវឱ្យរាជធានីនិងខេត្តនីមួយៗរកដី ដើម្បីធ្វើផែនការអនុវត្តឱ្យបានចំនួន ៥១៦ គ្រួសារ ក្នុងមួយឆ្នាំ ។ ខេត្តចំនួន១២ បានកំណត់រួចហើយនូវមុខសញ្ញាដីសរុបទំហំ ៣៦ ៩១៧ ហិកតា និងមុខសញ្ញាគ្រួសារប្រជាពលរដ្ឋក្រីក្រគ្មានដី ចំនួន ១៤ ៧៩១ គ្រួសារ។ ខេត្តដែលបានអនុវត្តការបែងចែកដីរួចហើយ រួមមាន៖

- ខេត្តកំពង់ចាម៖ ផ្ទៃដីទំហំ៨៦៣ ,៦៥ ហិកតា ដល់ ២៤៦ គ្រួសារក្រីក្រ ។

- ខេត្តក្រចេះ ៖ ផ្ទៃដីទំហំ៣៩០៦ហិកតាដល់ ២៩៦គ្រួសារក្រីក្រ និងបន្តពិនិត្យផ្តល់ដល់៣៥០គ្រួសារទៀត។
- ខេត្តឧត្តរមានជ័យ: ផ្ទៃដីទំហំ ១២៩ហិកតា ចែកដល់៩៥គ្រួសារក្រីក្រ។
- ខេត្តកំពត: ផ្ទៃដីទំហំ ១០១១៩ហិកតា ចែកដល់៣១៧គ្រួសារក្រីក្រ។
- ខេត្តកំពង់ចាម: ផ្ទៃដីទំហំ ១៥៥ហិកតា ចែកដល់១០០គ្រួសារក្រីក្រ។
- ខេត្តព្រះវិហារ: ផ្ទៃដីច្រើនជាង១៨០០០ហិកតា ចែកដល់១៨០២គ្រួសារកងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋនៅតំបន់ប្រាសាទព្រះវិហារ តំបន់ភាគខាងលិច និងតំបន់ពាយ័ព្យនៃប្រទេសតាមបណ្តោយព្រំដែនកម្ពុជា-ថៃ សរុប ចំនួន ១ ៨០២ គ្រួសារ ដោយរៀបចំជាភូមិអភិវឌ្ឍន៍ថ្មី។

៨- រាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរលេខ០៣ សរ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ដើម្បីណែនាំដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងស្ថាប័នពាក់ព័ន្ធ អំពីនីតិវិធីដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន ដែលបានកើតនៅតាមទីក្រុងនិងទីប្រជុំជន។ សារាចរនេះដាក់ចេញនូវវិធានការជាក់លាក់សម្រាប់អ្នកដែលត្រូវទៅរស់នៅលើទីតាំងថ្មី ដូចជា :

១- ការស្រង់ទិន្នន័យជាក់លាក់អំពីចំនួនទីតាំងសំណង់បណ្តោះអាសន្ន
២- ការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ទីតាំងដីដែលសំណង់បណ្តោះអាសន្នតាំងនៅ
៣- ការធ្វើជំរឿនគ្រួសារ និងចំនួនប្រជាជនដែលរស់នៅក្នុងទីតាំងដីសំណង់បណ្តោះអាសន្ន
៤- ការស្វែងរកដំណោះស្រាយ
៥- ការពិភាក្សាសម្របសម្រួលដើម្បីកំណត់គោលនយោបាយ
៦- ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈមូលដ្ឋានចាំបាច់សម្រាប់គាំទ្រដល់ការរស់នៅ និង
៧- ការចូលរួមរបស់ភាគីពាក់ព័ន្ធ

៩- រហូតមកទល់ពេលនេះ ដោយសារថវិកាមានកម្រិតមិនទាន់មានការប៉ាន់ប្រមាណអំពីផលប៉ះពាល់នៃអស្ថេរភាពនៃសិទ្ធិកាន់កាប់ដីធ្លីទៅលើសមត្ថភាពរបស់គ្រួសារ នៅក្នុងការចិញ្ចឹមបីបាច់ថែរក្សាបុត្រធិតាទេ។

*សំណួរទី ១៤- សូមផ្តល់ព័ត៌មានអំពីវិធានការដែលបានប្រកាន់យកដើម្បីកាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សាខ្ពស់ បង្កើនការចុះឈ្មោះចូលរៀនរបស់កុមារីនៅកម្រិតមធ្យមសិក្សា កែលំអគុណភាពនៃការសិក្សានិងសមត្ថភាពគរុកោសល្យរបស់គ្រូបង្រៀននិងអភិវឌ្ឍការអប់រំមត្តេយ្យសាលា (Early Childhood Education)។ សូមផ្តល់ព័ត៌មានជូនគណៈកម្មាធិការផងដែរ អំពីវិធានការដែលបានប្រកាន់យកដើម្បីធានាសិទ្ធិទទួលបាននូវការសិក្សាចំពោះកុមារដែលមិននិយាយភាសាខ្មែរ។*

**ចម្លើយ** :

**១- វិធានការប្រកាន់យកដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សា** :

ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣ មានយុទ្ធសាស្ត្រកាត់បន្ថយអត្រាត្រួតថ្នាក់និងបោះបង់ការសិក្សានៅគ្រប់កម្រិតថ្នាក់និងបង្កើនចំនួនអាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ សិស្សក្រីក្ររៀនពូកែ ជាពិសេសសិស្សស្រីដើម្បីធានាបានការចូលរៀននៅមធ្យមសិក្សា។ ឆ្លើយតបនឹងយុទ្ធសាស្ត្រខាងលើនេះ ក្រសួងបាននិងកំពុងអនុវត្តកម្មវិធីអនុវិទ្យាល័យនៅតាមឃុំ សង្កាត់ និងវិទ្យាល័យនៅតាមស្រុកខណ្ឌដែលមានតម្រូវការ។ មកដល់ឆ្នាំសិក្សា២០១០-២០១១នេះ ឃុំសង្កាត់ ១៤៧២ ស្មើនឹង ៩០,៨ ភាគរយនៃចំនួនឃុំ-សង្កាត់សរុប១៦២១ មានអនុវិទ្យាល័យនិងក្រុង ស្រុក ខណ្ឌ១៨២ ស្មើ៩៤,៣ភាគរយ នៃចំនួនក្រុង ស្រុក ខណ្ឌ ១៩៣ មានវិទ្យាល័យ។ **ក្រសួងអប់រំ យុវជន និងកីឡា**បាននិងកំពុងអនុវត្តកម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សដោយផ្អែកលើអត្តសញ្ញាណសិស្សក្រីក្រ សិស្សរៀនពូកែ ពិសេសសិស្សស្រី។ ក្នុងឆ្នាំសិក្សា ២០១០-២០១១ សិស្សដែលទទួលបានអាហារូបករណ៍នៅមធ្យមសិក្សាមានចំនួន ៤៦ ១៩២នាក់ ស្រី ២៧ ២៦៥ នាក់។ ដើម្បីអនុវត្តកម្មវិធីនេះឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងរៀបចំព្រាងគោលនយោបាយ ស្តីពីអាហារូបករណ៍នៅមធ្យមសិក្សា។ ក្រសួងមានកម្មវិធីផ្តល់អាហារពេលព្រឹកដល់សាលាបឋមសិក្សាដែលមានសាលាចំនួន ១ ៣០០ សិស្ស ៤៩០ ៥៦៣ នាក់ ក្នុងនោះមានសិស្សស្រី ២៤០ ២២៣ នាក់។

**២- ការកែលម្អគុណភាពនៃការសិក្សា និងសមត្ថភាពគរុកោសល្យរបស់គ្រូបង្រៀន** :

**ក្រសួងអប់រំ យុវជន និងកីឡា**បានកែលម្អគោលនយោបាយកម្មវិធីសិក្សាពីរយៈពេល ២០០៥-២០០៩ ទៅ ២០១០-២០១៤ ដោយបានកំណត់យកការបង្រៀនបំណិនជីវិត ជាមុខវិជ្ជាចាំបាច់ការបង្រៀនភាសាបរទេសអង់គ្លេសឬបារាំងចាប់ពីថ្នាក់ទី៤នៃបឋមសិក្សា ហើយសិស្សថ្នាក់ទី១១និង១២ត្រូវជ្រើសរើសយកថ្នាក់វិទ្យាសាស្ត្រឬវិទ្យាសាស្ត្រសង្គមដើម្បីរៀននិងមានការកំណត់ស្តង់ដាជាតិនៅថ្នាក់ទី៣ ទី៦ ទី៩ និងទី១២ ដើម្បីធ្វើការវាយតម្លៃសមត្ថភាពនិងការយល់ដឹងរបស់សិស្ស។ នៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិគឺចាប់ពីថ្នាក់ទី១-៩ ដើម្បីអនុវត្តតាមមាត្រា៦៥នៃរដ្ឋធម្មនុញ្ញ ដែលចែងថា ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិច ០៩ឆ្នាំ រាជរដ្ឋាភិបាលបានបង្កើតនិងអនុវត្តគោលនយោបាយស្តីពីសាលាកុមារមេត្រី ដោយផ្តោតលើសមាសភាគចំនួន០៦ធំៗ គឺ **ក**-កុមារ ទាំងអស់បានចូលរៀន **ខ**-ការសិក្សាប្រកបដោយប្រសិទ្ធភាព **គ**-សុខភាពសុវត្ថិភាព និងការការពារកុមារ **ឃ**-ការឆ្លើយតបទៅនឹងយេនឌ័រ **ង**-ការចូលរួមរបស់គ្រួសារកុមារ និងសហគមន៍ និង **ច**-ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ ។ ក្នុងឆ្នាំសិក្សា ២០១០-២០១១ សាលាបឋមសិក្សាមាន ៦៧៦៧ ក្នុងនោះសាលាកុមារមេត្រីមាន ៣៨៩១ ស្មើនឹង ៥៨ ភាគរយ ។ បើប្រៀបធៀបនឹងឆ្នាំ២០១០ ឃើញថាចំនួនសាលាកុមារមេត្រីមានកំណើនប្រមាណ ០១ភាគរយ ។ នៅមធ្យមសិក្សាបឋមភូមិសាលាកុមារ

មេត្រីអនុវត្តបាន ៤២៤ ស្មើនឹង ៣៦ ភាគរយ ក្នុងចំណោមអនុវិទ្យាល័យ ១១៧២។ ក្រៅពីនេះ ក្រសួងក៏បានរៀបចំកម្មវិធីប្រឡងជ្រើសរើសជ័យលាភីសិស្សពូកែទូទាំងប្រទេសជារៀងរាល់ឆ្នាំ ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យានៅថ្នាក់ទី៩ និងទី១២ ដោយជ្រើសរើសយក ១០នាក់ ក្នុងមួយមុខវិជ្ជានិងមួយកម្រិតថ្នាក់។ ក្រសួងក៏បានបញ្ជូនសិស្សចូលរួមប្រកួតប្រជែងការប្រឡងជាលក្ខណៈអន្តរជាតិ ដូចជាការប្រឡងផ្នែករូបវិទ្យា អូឡាំព្យាដអន្តរជាតិលើកទី១១ គណិតវិទ្យាអូឡាំព្យាដអន្តរជាតិលើកទី៥១ តារារូបអូឡាំព្យាដអន្តរជាតិលើកទី៦ និងផែនដីវិទ្យាអូឡាំព្យាដអន្តរជាតិលើកទី៤ ។ គ្រប់ការប្រឡងសិស្សទទួលបានជ័យលាភីនិងមេដាយ ។

**៣- ការពង្រឹងសមត្ថភាពគ្រូបង្រៀន**

ក្រសួងបានរៀបចំស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមាន៤សមាសភាគគឺចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ និងបានកសាងផែនការគោលសម្រាប់អភិវឌ្ឍគ្រូបង្រៀនរយៈពេលពី២០១០-២០១៤ ។ គ្រូបង្រៀនត្រូវឆ្លងកាត់ការប្រឡងជ្រើសរើស ដើម្បីទទួលការបណ្តុះបណ្តាល និងមានការចុះធ្វើកម្មសិក្សា ។ ពេលបញ្ចប់វគ្គបណ្តុះបណ្តាលមានការប្រឡងបញ្ចប់ ដើម្បីជ្រើសរើសកន្លែងដែលត្រូវទៅបំពេញភារកិច្ច។

អ្នកគ្រប់គ្រងសាលារៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ បានទទួលការពង្រឹងសមត្ថភាពផងដែរ។ កម្មវិធីបណ្តុះបណ្តាលគ្រូបឋមសិក្សា និងមត្តេយ្យសិក្សាត្រូវបានកែលម្អ ដោយបន្ថែមម៉ោងលើមុខវិជ្ជាគណិតវិទ្យា ភាសាខ្មែរ និងការអប់រំសិល្បៈដល់គ្រូមត្តេយ្យសិក្សា និងបញ្ចូលមុខវិជ្ជាបរិស្ថាន ការអប់រំបញ្ចូលគ្នា និងការសិក្សាតាមបែបស្រាវជ្រាវដល់គ្រូបឋមសិក្សា ។

**៤- មត្តេយ្យសិក្សា**

ក្រសួងបានរៀបចំគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលទទួលបានការឯកភាពពីរាជរដ្ឋាភិបាលនៅឆ្នាំ២០១០។ គោលនយោបាយនេះ ជួយពង្រឹងកិច្ចសហប្រតិបត្តិការពីបណ្តាក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍដល់ការអនុវត្តកម្មវិធីអប់រំកុមារតូចឱ្យកាន់តែប្រសើរឡើង ។ ពីមុនមកការអប់រំកុមារតូចមានតែនៅតាមសាលាមត្តេយ្យរដ្ឋតែប៉ុណ្ណោះ ។ បន្ទាប់ពីមានយុទ្ធសាស្ត្រពង្រីកលទ្ធភាពចូលរួមរបស់ផ្នែកឯកជន និងសហគមន៍នៅគ្រប់កម្រិតសិក្សា ជាពិសេសក្រុមប្រឹក្សាឃុំសង្កាត់ ការផ្តល់សេវាអប់រំដល់កុមារតូច មានការរីកចម្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ក្នុងឆ្នាំសិក្សា ២០១០-២០១១ មត្តេយ្យសិក្សារដ្ឋមាន២០៩២ សហគមន៍មាន ១៧៦៦កន្លែង និងមត្តេយ្យសិក្សាឯកជនមាន ២៥៦ ។ ជារួមនៅទូទាំងប្រទេស សាលាមត្តេយ្យមានចំនួន៤១១៤ ហើយកុមារអាយុពី០-ទៅក្រោម ៦ឆ្នាំ ចំនួន ២៣៤ ៤២៩ នាក់ ស្រី ១១៧ ៩៩៣ នាក់ បានទទួលការអប់រំ។

**៥- សិទ្ធិទទួលបានការសិក្សាចំពោះកុមារដែលមិននិយាយភាសាខ្មែរ**

គោលនយោបាយកម្មវិធីសិក្សា បានកំណត់យកភាសាខ្មែរជាយានក្នុងការបង្រៀនសិស្សនៅតាមសាលា។ ដើម្បីជួយដល់សិស្សជនជាតិភាគតិច ក្រសួងបានរៀបចំជាកម្មវិធីអប់រំពីរភាសាទាំងមត្តេយ្យសិក្សា ទាំងបឋមសិក្សា ដោយមានការឧបត្ថម្ភពីអង្គការនានា។ កម្មវិធីនេះបានអនុវត្តនៅខេត្តស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី មានសាលារៀនចំនួន២៧ សិស្សសរុប២៣៥៩នាក់ ស្រី១០៥៤នាក់។ ការបង្រៀន និងរៀនជាពីរភាសា អនុវត្តតែពីថ្នាក់ទី១-៣តែប៉ុណ្ណោះ ហើយចាប់ពីថ្នាក់ទី៤ឡើងទៅ សិស្សត្រូវបានរៀន និងបង្រៀនជាភាសាជាតិ ដូចសិស្សទូទៅវិញព្រោះក្នុងរយៈពេល០៣ឆ្នាំ សិស្សទាំងនោះអាចចេះអាន និងសរសេរអក្សរខ្មែរបានត្រឹមត្រូវ។

ក្រៅពីការកសាងសមត្ថភាពដោយផ្ទាល់ដល់គ្រូបង្រៀន និងការប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំនៅឆ្នាំ២០០៧ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀននៅឆ្នាំ២០០៨ ។ ជាលទ្ធផលសង្កេតឃើញថា ឥរិយាបទរបស់គ្រូបង្រៀនមានការផ្លាស់ប្តូរ ហើយដំណើរការសិក្សារៀនសូត្រក៏បានប្រសើរឡើងដែរ។

*សំណួរទី ១៥ - សូមផ្តល់ទិន្នន័យបំបែកតាមប្រភេទ អំពីចំនួនកុមារដែលត្រូវបានឃុំឃាំង នៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទា និងព័ត៌មានលំអិតអំពីមូលដ្ឋានច្បាប់នៃការឃុំឃាំងនោះ ស្ថានភាពរស់នៅរបស់ពួកគេ និងអំពីអាជ្ញាធរដែលទទួលខុស ត្រូវក្នុងការត្រួតពិនិត្យមជ្ឈមណ្ឌលទាំងអស់នោះ។ សូមផ្តល់ព័ត៌មានថាតើមាន ការស៊ើបអង្កេតអ្វីទាក់ទងទៅនឹងការដែលមានការចោទប្រកាន់ថាកុមារអនាថា និងកុមារដែលគ្មានផ្ទះសម្បែងច្រើន តែត្រូវបានគេចាប់យកមកដាក់ឃុំឃាំងនៅក្នុង មជ្ឈមណ្ឌលទាំងអស់នោះ និងការដែល ថាកុមារដែលរស់នៅក្នុងទីទាំងអស់នោះតែងតែត្រូវបានគេវាយដំធ្វើទារុណកម្ម និងថែទាំមិនបានល្អ(ill treatment)។ សូមផ្តល់ព័ត៌មានជូនគណៈកម្មាធិការផងដែរអំពីការរីកចម្រើនឆ្ពោះទៅរកការអភិវឌ្ឍនូវសេវាព្យាបាល សេវាស្តារនីតិសម្បទា និងសេវាថែទាំក្រោយការព្យាបាលនៅតាមសហគមន៍ ចំពោះការញៀនសារធាតុញៀន ។*

**ចម្លើយ** :

១- ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាមិនបានចាត់ទុកថាមជ្ឈមណ្ឌលយុវនីតិសម្បទាជាកន្លែងឃុំឃាំងមនុស្សនោះឡើយ។ ឧទាហរណ៍ដូចជាវាក្យខ័ណ្ឌទី៥នៃមាត្រាទី៦ របស់ប្រកាសលេខ៤៧០ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦ ស្តីពីលក្ខណ្ឌនិងនីតិវិធីទទួលយក គ្រប់គ្រង និងស្តារនីតិសម្បទាកុមារ និងយុវជននៅក្នុងមជ្ឈមណ្ឌលស្តារយុវនីតិសម្បទាចោមចៅ បានទាមទារឲ្យមានការយល់ព្រមពីកុមារផង និងពីមាតាបិតាផង សម្រាប់ការស្នាក់នៅក្នុងមជ្ឈមណ្ឌលនេះ ។ ទិន្នន័យកុមាររស់នៅក្នុងមជ្ឈមណ្ឌលយុវនីតិសម្បទា ចំណុះក្រសួង ស.អ.យ នៅ ឆ្នាំ២០០៩ និងឆ្នាំ២០១០ រួមមាន ៖

| ឈ្មោះមជ្ឈមណ្ឌល | ឆ្នាំ២០០៩ | ឆ្នាំ ២០១០ | សេវាព្យាបាលនិង ស្តារនីតិសម្បទា | សេវាថែទាំ បន្ទាប់ | ចំនួនសរុប |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| មជ្ឈមណ្ឌលយុវនីតិសម្បទាចោមចៅ | ៤៦ នាក់ | ០៧ នាក់ | ៥៣នាក់ | ៥៣នាក់ | ៥៣នាក់ |
| មជ្ឈមណ្ឌលយុវសម្បទាជីវិតថ្មីកំពង់កន្ទួត ខេត្តកណ្តាល | ១៧នាក់ | ០ | ១៧នាក់ | ០ | ១៧នាក់ |
| មជ្ឈមណ្ឌលជីវិតថ្មីស្មាច់មានជ័យខេត្តកោះកុង | ២៥ នាក់ | ៣១នាក់ | ៥៦ នាក់ | ៤៧ នាក់ | ៥៦ នាក់ |
| មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ ខេត្តបន្ទាយមានជ័យ | ៥៨នាក់ | ១០៣នាក់ | ១៦១នាក់ | ៣៦នាក់ | ១៦១នាក់ |
| សរុបរួម | ១៤៦នាក់ | ១៤១នាក់ | ២៨៧នាក់ | ១៣៦នាក់ | ២៨៧នាក់ |

**២-មូលដ្ឋានច្បាប់និងអាជ្ញាធរដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យមជ្ឈមណ្ឌល :**

ការគ្រប់គ្រងកុមារនៅក្នុងមជ្ឈមណ្ឌលយុវនីតិសម្បទាខាងលើផ្អែកលើមូលដ្ឋានច្បាប់ដូចខាងក្រោម :

ក- ច្បាប់ស្តីពីការបង្កើតក្រសួង ស.អ.យ

ខ-ប្រកាសលេខ៣០៤ ស.ក.ប.យ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០ របស់ក្រសួង ស.អ.យ ស្តីពីការបង្កើតមជ្ឈមណ្ឌលយុវនីតិសម្បទាចោមចៅ។

គ-ប្រកាសលេខ៤៧០ ស.អ.យ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦ របស់ក្រសួង ស.អ.យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការទទួលគ្រប់គ្រងនិងស្តានីតិសម្បទាកុមារ នៅមជ្ឈមណ្ឌលយុវនិតិសម្បទាចោមចៅ។

ឃ-ប្រកាសលេខ៣៤១ ស.អ.យ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ របស់ក្រសួង ស.អ.យ ស្តីពីការបង្កើតមជ្ឈមណ្ឌលយុវនីតិសម្បទាកំពង់កន្ទួត។

ង-ប្រកាសលេខ១០៨ ស.អ.យ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ក្រសួង ស.អ.យ ស្តីពីបង្កើតមជ្ឈមណ្ឌលជីវិតថ្មីស្មាច់មានជ័យ។

អាជ្ញាធរដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យមជ្ឈមណ្ឌលទាំងនេះគឺក្រសួង ស.អ.យ។ បច្ចុប្បន្នក្រសួង ស.អ.យ កំពុងពិនិត្យប្រកាសខាងលើ និងគោលការណ៍របស់មជ្ឈមណ្ឌលស្តារនីតិសម្បទា យុវជនឡើងវិញ ដើម្បីឱ្យសមស្របទៅនឹងច្បាប់ថ្មីៗនិងសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។

**៣-ស្ថានភាពរស់នៅរបស់កុមារក្នុងមជ្ឈមណ្ឌលយុវនីតិសម្បទា**

ដំណាលគ្នានឹងការខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌កុមារដ៏ទូលំទូលាយមួយ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់លើការផ្តល់សេវាដល់កុមារទំនាស់នឹងច្បាប់ដែលត្រូវការសេវាស្តារនីតិសម្បទាដើម្បីដោះស្រាយបញ្ហាបន្ទាន់នៅចំពោះមុខ។ ស្ថានភាពកុមារក្នុងមណ្ឌលយុវនីតិ

សម្បទា មានលក្ខណៈល្អប្រសើរបើប្រៀបធៀបនឹងបណ្តាឆ្នាំកន្លងមក។ មានការថែទាំសុខភាព ជីវភាព អនាម័យ មានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកីឡា។ មន្ត្រីបម្រើការនៅតាមមជ្ឈមណ្ឌលទាំងនោះបានទទួលនូវការបណ្តុះបណ្តាលជាបន្តបន្ទាប់ហើយសមត្ថភាពក្នុងការធ្វើការជាមួយកុមារទំនាស់នឹងច្បាប់ត្រូវបានពង្រឹង។

៤- ក្រសួង ស.អ.យ បានស្វាគមន៍ និងទទួលយកនូវសេចក្តីសង្កេតសម្ងាត់ជំហ៊ានដំបូងនៃការធ្វើទស្សនៈកិច្ចរបស់អនុគណៈកម្មាធិការបង្ការទារុណកម្ម (SPT) នៅព្រះរាជាណាចក្រកម្ពុជាទៅលើមជ្ឈមណ្ឌលយុវនីតិសម្បទា កាលពីថ្ងៃទី០២ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩។ ក្រសួងស.អ.យ បានចាត់តាំងក្រុមការងារដើម្បីធ្វើការស៊ើបអង្កេត និងឆ្លើយតបទៅនឹងការចោទប្រកាន់ថា កុមារអនាថានិងកុមារគ្មានផ្ទះសម្បែងជាច្រើនត្រូវបានគេចាប់យកមកដាក់ឃុំឃាំងនៅក្នុងមជ្ឈមណ្ឌលទាំងនោះ។ បន្ទាប់មកនៅខែកញ្ញា ឆ្នាំ២០១០ ក្រសួង ស.អ.យ បានសហការជាមួយអង្គការយូនីសេហ្វនិងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា សម្រេចជ្រើសរើសទីប្រឹក្សាវាយតម្លៃដើម្បីវាយតម្លៃការអនុវត្តគោលនយោបាយ ការគ្រប់គ្រង និងការផ្តល់សេវាដល់ជនងាយរងគ្រោះនៅក្នុងមជ្ឈមណ្ឌល យុវនីតិសម្បទាទាំងនោះ ក្នុងគោលបំណងកែលម្អគោលនយោបាយ និងការអនុវត្តឆ្លើយតបទៅនឹងតម្រូវការរបស់កុមារទាំងនោះឲ្យមានប្រសិទ្ធភាព។

ការវាយដំធ្វើទារុណកម្មនិងការប្រព្រឹត្តមិនត្រឹមត្រូវត្រូវបានហាមឃាត់។ បុគ្គលដែលប្រព្រឹត្តអំពើទាំងនេះត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន។

**៥- ការញៀនសារធាតុញៀន**

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៦២អនក្រ.បកចុះថ្ងៃទី២២ខែធ្នូឆ្នាំ២០១០ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។ ក្រសួង ស.អ.យ បានចេញប្រកាសលេខ ៦៣៤ ស.អ.យ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ ក្រសួងនឹងបន្តរៀបចំនីតិវិធីនិងលិខិតបទដ្ឋានមួយចំនួនទៀតដែលពាក់ព័ន្ធដំណើរការព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀននៅក្នុងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ មកដល់ចុងឆ្នាំ២០១០ អាជ្ញាធរជាតិប្រឆាំងគ្រឿងញៀនបានអនុវត្តសាកល្បងនូវផែនការប្រតិបត្តិការប្រឆាំងគ្រឿងញៀនមួយដែលមានសមាសភាគចំនួន០៤ រួមទាំងការព្យាបាលតាមសហគមន៍នៅក្នុងខេត្តបន្ទាយមានជ័យ។ នៅមិនទាន់មានរបាយការណ៍សកម្មភាពនៅឡើយទេ នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។

***សំណួរទី ១៦ - សូមផ្តល់ព័ត៌មានអំពីសមិទ្ធិផលនៃការអនុវត្តផែនការជាតិប្រឆាំងនឹងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ២០០៦-២០១០។ សូមធ្វើការអធិប្បាយលើព័ត៌មានដែលនិយាយថា១ភាគ៣នៃស្ត្រីពេស្យានៅ***

*ក្នុងរដ្ឋភាគី គឺជាកុមារ និងបញ្ជាក់អំពីវិធានការជាក់ស្តែងដែលបានប្រកាន់យកដើម្បីដកហូតយកកុមារទាំងអស់នោះចេញពីពេស្យាចារ្យ។*

**ចម្លើយ** :

១- ការអនុវត្តផែនការជាតិប្រឆាំងនឹងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទផែនការជាតិទី០១ ឆ្នាំ២០០០-២០០៤: ផែនការនេះត្រូវបានអនុវត្តចប់ទាំងស្រុង ដូចមានបង្ហាញជូននៅក្នុងរបាយការណ៍លើកទី២និងទី៣ របស់ កម្ពុជាស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារត្រង់ចំណុចទី២០៤ ដល់ចំណុចទី២៤២។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានធ្វើការវាយតម្លៃលើការអនុវត្តផែនការនេះនៅឆ្នាំ២០០៥។ ចំពោះសមិទ្ធិផលផ្សេងទៀត សូមមើលឧបសម្ព័ន្ធទី១នៃរបាយការណ៍។

ផែនការជាតិទី២ ឆ្នាំ២០១១-២០១៤: រហូតមកទល់ឆ្នាំ២០១០ មិនទាន់មានផែនការជាតិថ្មីមកជំនួសផែនការចាស់ឡើយ។ ផែនការជាតិលើកទី២ បានរៀបចំរួចរាល់ និងរង់ចាំការសម្រេចពីរាជរដ្ឋាភិបាល។

ក្នុងអំឡុងពេលរង់ចាំផែនការជាតិលើកទី២នេះ ព្រះរាជាចក្រកម្ពុជាសម្រេចបាននូវសមិទ្ធិផលយ៉ាងច្រើន ជាអាទិ៍ :

**ក- ការរៀបចំច្បាប់ បទដ្ឋាន និងគោលនយោបាយ** :

- ព្រះរាជក្រមលេខ នស/រកម/០១១០/០០១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាអាស៊ានស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុង វិស័យព្រហ្មទណ្ឌ។
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- ក្រមនីតិវិធីព្រហ្មទណ្ឌប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ច្បាប់ស្តីពីទេសចរណ៍ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩
- ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/ ១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩

**រាជរដ្ឋាភិបាលបានចេញ ៖**

ក. គោលការណ៍ណែនាំលេខ០០១ សណន បដរភព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ខ. សេចក្តីសម្រេចលេខ ៥៧សសរ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការ បង្កើតក្រុមការងារចម្រុះ ពិនិត្យ ចំណាត់ការរឿងក្តីព្រហ្មទណ្ឌ នៅតាមអង្គភាព អនុវត្តច្បាប់នានា។

គ- អនុក្រឹត្យលេខ១៨៣អនក្រ.បក ចុះថ្ងៃ០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ស្តីពីការកំណត់បែបបទ និងនីតិវិធី នៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរនិង ជនបរទេស និង សេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការអនុវត្តអនុក្រឹត្យនេះ។

ដោយឡែកក្រសួងមហាផ្ទៃបានចេញសេចក្តីសម្រេចលេខ ២៧២៩សសរ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងារចម្រុះច្រកចេញចូលតែមួយសម្រាប់ពិនិត្យចុះបញ្ជិការរៀប អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ។

**ក្រសួងយុត្តិធម៌បានចេញ** :

**ក-** សេចក្តីណែនាំលេខ០១ កយសណន/០៩ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០០៩ ស្តីអំពីការអនុវត្ត មាត្រា៤២ " អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ " និងមាត្រា៤៣ " អំពើអាសប្រឆាំង នឹងអនីតិជនអាយុក្រោម១៥ឆ្នាំ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ"។

**ខ-** ប្រកាសលេខ ៦២ កយប្រក/០៨ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨ស្តីពីការប្រើប្រាស់របាំងក្នុងបន្ទប់ សវនាការនិងបន្ទប់សវនាការភ្ជាប់បណ្តាញទូរទស្សន៍ ដើម្បីយកសក្ខីកម្មពីកុមារឬជនរងគ្រោះឬ សាក្សីដែលងាយរងគ្រោះ។

**គ-** លិខិតលេខ១១៩១ កយរប.០១ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ណែនាំឲ្យសាលាដំបូង និង អយ្យការរាជធានីខេត្ត ស្រង់ទិន្នន័យរឿងក្តីរំលោភសេពសន្ថវៈ និងអំពើហឹង្សាក្នុងគ្រួសារ ដើម្បី ផ្ញើមកក្រសួងបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ។

**ឃ-** សេចក្តីសម្រេចលេខ១២កយសសរ១០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០បង្កើតក្រុមការងារគ្រប់គ្រង និងវិភាគសំណុំរឿងក្តីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**ក្រសួងទេសចរណ៍បានចេញ** :

**ក-** ប្រកាសលេខ ០៧៦ ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ ដល់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន។

**ខ-** សារាចរណែនាំលេខ ០០៣ សរណន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងអាជីវកម្ម ភោជនីយដ្ឋាន និងអាហារដ្ឋាន។

**គ-** ប្រកាសលេខ ០៧៥ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ ដល់អាជីវកម្មសេវាកម្មម៉ាស្សាសុខភាព-ស្ប៉ា

**ឃ**- សារាចរណ៍ណែនាំលេខ ០០៨សរណន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មម៉ាស្សាសុខភាព-ស៉្បា

**ង**- ប្រកាសលេខ ០៧៨ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្មខារ៉ាអូខេ

**ច**- សារាចរណ៍ណែនាំលេខ០០២សរណន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងអាជីវកម្មខារ៉ាអូខេ។

**ឆ**- សារាចរណ៍ណែនាំលេខ០០១សរណន ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០១០ ស្តីពីការគ្រប់គ្រងមូលដ្ឋានអាជីវកម្ម សេវាកម្ម កម្សាន្ត ទេសចរណ៍។

សារាចរណែនាំទាំងអស់ខាងលើសុទ្ធតែមានបទប្បញ្ញត្តិហាមឃាត់រាល់សកម្មភាពធ្វើអាជីវកម្មជួញដូរគ្រឿងញៀន ការកេងប្រវញ្ចផ្លូវភេទលើកុមារ អំពើពេស្យាចារគ្រប់ប្រភេទ ការបើកបនល្បែងស៊ីសងជ្រកក្រោមរូបភាពអាជីវកម្ម និងហាមអនីតិជនចូលកម្សាន្តក្នុងទីតាំងអាជីវកម្ម។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឆ្នាំ២០០៨-២០១២។

អគ្គស្នងការនគរបាលជាតិបានចេញសេចក្តីសម្រេចលេខ ០០៥ ស.ណ.ន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ ស្តីពីការបង្ក្រាបការប្រើប្រាស់គ្រឿងញៀនតាមកន្លែងកម្សាន្ត ការជួញដូរមនុស្ស និងការលេងល្បែងភ្នាល់គ្មានការអនុញ្ញាត និងសេចក្តីណែនាំលេខ០០៩ស.ណ.ន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០ ស្តីពីការអនុវត្តប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។

ក្រសួងមហាផ្ទៃបានចេញគោលការណ៍ណែនាំស្តីពីភូមិឃុំមានសុវត្ថិភាពដែលមានខ្លឹមសារដូចខាងក្រោម :

១- គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ

២- គ្មានការផលិត ចែកចាយ ប្រើប្រាស់គ្រឿងញៀនគ្រប់ប្រភេទ

៣- គ្មានពំពើអនាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើហឹង្សាក្នុងគ្រួសារ

៤- គ្មានក្មេងទំនើង

៥- គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

ការអនុវត្តគោលនយោបាយនេះ បាននិងកំពុងដើរតួនាទីគន្លឹះក្នុងការបង្ការទប់ស្កាត់និងបង្ក្រាបបទល្មើសនៅតាមបណ្តាភូមិឃុំទូទាំងប្រទេស បង្កើតសំណាញ់សុវត្ថិភាព និងបណ្តាញអនុវត្តច្បាប់ដែលមានប្រសិទ្ធិភាព។

២- ពុំទាន់មានការអង្កេតទូលំទូលាយដែលកំណត់ថា១ភាគ៣នៃស្ត្រីពេស្យានៅកម្ពុជាគឺជាកុមារទេ។ ប៉ុន្តែនៅកម្ពុជាច្បាប់ហាមខាត់មិនឲ្យមានអំពើពេស្យាចារកុមារឡើយ។

*សំណួរទី ១៧ - សូមផ្តល់ព័ត៌មានបច្ចុប្បន្នកម្មអំពីការរីកចម្រើនឆ្ពោះទៅរកការរៀបចំបង្កើតឲ្យមានប្រព័ន្ធយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់មួយដែលមានរួមទាំងការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ផងដែរ។ សូមពន្យល់ផងដែរអំពីមូលហេតុនៃការកើនឡើងនៃចំនួនកុមារដែលត្រូវរងការឃុំឃាំងនៅក្នុងពេលប៉ុន្មានឆ្នាំក្រោយនេះ និងបញ្ជាក់អំពីវិធានការដែលបានប្រកាន់យកដើម្បីធានាថាសិទ្ធិកុមារត្រូវបានគេគោរពនៅក្នុងគ្រប់ដំណាក់កាលនៃការស៊ើបអង្កេត ការចាប់/ឃាត់ខ្លួន ការឃុំខ្លួន និងថាកុមារលែងត្រូវបានឃុំឃាំងជាមួយនឹងមនុស្សចាស់។*

**ចម្លើយ** :

១- សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានកែសម្រួលចុងក្រោយដោយធ្វើការពិនិត្យអនុសាសន៍របស់មូលនិធិសហប្រជាជាតិដើម្បីកុមារ។ សេចក្តីព្រាងច្បាប់នេះត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមបទដ្ឋានអន្តរជាតិ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមានការចូលរួមផ្តល់យោបល់ពីដៃគូអភិវឌ្ឍ មូលនិធិសហប្រជាជាតិដើម្បីកុមារ និងអង្គការសង្គមស៊ីវិល។ ស្របគ្នានឹងសេចក្តីព្រាងច្បាប់នេះ បទបញ្ជា ទម្រង់ បញ្ជីត្រួតពិនិត្យ និងឧបករណ៍ផ្សេងៗទៀតសម្រាប់នគរបាលមេធាវី ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជំរះ ភ្នាក់ងារសង្គមកិច្ច មន្ត្រីពន្ធនាគារ និងមន្ត្រីស្តារនីតិសម្បទាផ្សេងៗទៀតក៏កំពុងរៀបចំ។ សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីរបៀបចាត់ការចំពោះកុមាររងគ្រោះ និងកុមារជាសាក្សីនៅក្នុងប្រព័ន្ធយុត្តិធម៌ កំពុងត្រូវបានពិនិត្យ។ ក្រសួង ស.អ.យ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ កំពុងធ្វើការសិក្សាស្រាវជ្រាវ និងពិនិត្យមើលលទ្ធភាពក្នុងការបង្កើតច្បាប់ស្តីពីការការពារកុមារ ឬច្បាប់ស្តីពីសុខុមាលភាពកុមារ។ ក្រសួងយុត្តិធម៌ បានដាក់ឱ្យប្រើប្រាស់សាកល្បងបញ្ជីចុះរឿងក្តីអនីតិជននៅក្នុងតុលាការមួយនៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងយុត្តិធម៌បានផលិតវីដេអូសម្រាប់អប់រំណែនាំកុមាររងគ្រោះ កុមារជាសាក្សីនិងកុមារល្មើសនឹងច្បាប់ស្តីពីតួនាទីរបស់តួអង្គ យុត្តិធម៌ព្រហ្មទណ្ឌ។

២- មូលហេតុនៃការកើនឡើងនៃចំនួនកុមារដែលត្រូវឃុំឃាំង ការប៉ាន់ប្រមាណអំពីស្ថានភាពកុមារល្មើសនឹងច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ទើបនឹងបានចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវនៅខែមីនា ឆ្នាំ២០១១។

៣- វិធានការធានាថាសិទ្ធិកុមារត្រូវបានគោរព នៅគ្រប់ដំណាក់កាលនៃនីតិវិធី និង កុមារមិនត្រូវបានឃុំឃាំងជាមួយនឹងមនុស្សចាស់:

ក - ការអនុម័តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ។

ខ - ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងច្បាប់ស្តីពីការគ្រប់គ្រងពន្ធនាគារ។

គ- ការដាក់ឱ្យប្រើប្រាស់សាកល្បងបញ្ជីចុះរឿងក្ដីអនីតិជននៅក្នុងតុលាការ ។

ឃ- ការរៀបចំឲ្យមាននីតិវិធីកុមារមេត្រី និងតុលាការកុមារមេត្រី។

ង- ការពង្រឹងសមត្ថភាពស្ថាប័ន និងអ្នកអនុវត្តច្បាប់ : ចាប់តាំងពីឆ្នាំ២០០៦មក វគ្គបណ្តុះបណ្តាលមូលដ្ឋានស្តីពីសិទ្ធិកុមារ ច្បាប់ និងយុត្តិធម៌ត្រូវបានបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលរបស់សាលាមេធាវី និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការសម្រាប់បណ្តុះបណ្តាលដល់សិស្សមេធាវី និងចៅក្រម និងព្រះរាជអាជ្ញា កំពុងបម្រើការ។ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បានផលិតវីដេអូបណ្តុះបណ្តាល ០២ សម្រាប់មន្ត្រីតុលាការសម្ភាសន៍កុមាររងគ្រោះ និង កុមារប្រព្រឹត្តល្មើសនឹងច្បាប់។ គិតមកទល់ឆ្នាំ ២០០៩ ចំនួន ៥៤ភាគរយ នៃមន្ត្រីសង្គមកិច្ចថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និង៨៣ភាគរយ នៃមន្ត្រីសង្គមកិច្ចថ្នាក់ស្រុកបានទទួលវគ្គបណ្តុះបណ្តាលមូលដ្ឋាន និងជំនាញស្តីពីកិច្ចការសង្គម។មេរៀនស្តីអំពីតួនាទីមន្ត្រីសង្គមកិច្ចនៅក្នុងប្រព័ន្ធយុត្តិធម៌កុមារ ត្រូវបានដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលមូលដ្ឋាន និងថ្នាក់ជំនាញខាងសេវាសង្គមកិច្ចនៃ ក្រសួង ស.អ.យ។ ក្នុងឆ្នាំ២០០៩ មន្ត្រីសង្គមកិច្ច មន្ត្រីពន្ធនាគារ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមកពីរាជធានី ខេត្តចំនួន០៧បានទទួលការបំពាក់បំប៉នជំនាញ តាមរយៈការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងករណី និងការធ្វើផែនការសមាហរណកម្មកុមារប្រព្រឹត្តល្មើសនឹងច្បាប់។ ក្រសួងយុត្តិធម៌បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលពហុវិស័យស្តីពីយុត្តិធម៌កុមារសម្រាប់គ្រូបង្គោលចំនួន៣៥នាក់ ដែលជាមន្ត្រីតុលាការ សង្គមកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល។

ច- ការផ្តល់សេវាផ្នែកច្បាប់ : សេវាផ្នែកច្បាប់ផ្តល់ដោយគណៈមេធាវី និងអង្គការមិនមែនរដ្ឋាភិបាលផ្នែកច្បាប់។

ឆ- ការចុះត្រួតពិនិត្យពន្ធនាគារពីសំណាក់ព្រះរាជអាជ្ញា : ព្រះរាជអាជ្ញាមានភារកិច្ចចុះត្រួតពិនិត្យពន្ធនាគារនៅតាមរាជធានី ខេត្ត ក្នុងមួយខែ ០២ ដង ។

# ផ្នែកទី២

*សូមផ្តល់ព័ត៌មានបច្ចុប្បន្នកម្មទាក់ទងទៅនឹងសិទ្ធិកុមារ និងការអនុវត្តសិទ្ធិកុមារ ទោះជា ដោយប្រយោល ឬដោយផ្ទាល់ក្តី :*

*ក- ច្បាប់/ក្រម និងបទបញ្ញាថ្មីៗ*

*ខ- ស្ថាប័នថ្មីៗ (រួមទាំងអាណត្តិរបស់ស្ថាប័នទាំងនោះ) ឬ ការធ្វើកំណែទម្រង់ស្ថាប័ន*

*គ- គោលនយោបាយកម្មវិធី និងផែនការសកម្មភាពថ្មីៗ និងអំពីវិសាលភាព និងការផ្តល់ហិរញ្ញប្បទាន ដល់គោលនយោបាយ កម្មវិធីនិងផែនការសកម្មភាពទាំងអស់នោះផងដែរ។*

*ឃ- ការផ្តល់សច្ចាប័នថ្មីៗលើឧបករណ៍សិទ្ធិមនុស្សផ្សេងៗ។*

**ចម្លើយ** :

**ក- ច្បាប់/ក្រម និងបទបញ្ញាថ្មីៗមានជាអាទិ៍:**

- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១១/០០៥ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១១ សំដៅពិនិត្យបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ដែលគណៈកម្មាធិការសមាជយល់ឃើញថាជាបញ្ហាសំខាន់របស់ប្រទេសជាតិ។
- ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩។
- រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២៧ អនក្រ បក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ដោយកំណត់យកថ្ងៃទី២១ ខែកុម្ភៈ រៀងរាល់ឆ្នាំជាទិវាជាតិសុខភាពមាតា ទារក និងកុមារ ដើម្បីលើកស្ទួយសុខភាពរបស់កុមារ។
- រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង ដោយតម្រូវឲ្យក្រសួងស្ថាប័នរាជរដ្ឋាភិបាលដូចជាវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិផ្សេងទៀតនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងស.អ.យ ក្រសួងយុត្តិធម៌ និងក្រសួងសុខាភិបាល ជាអាទិ៍ ប្រមូល ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិ ទាក់ទងនឹង :

១- ការចុះអត្រានុកូលដ្ឋានប្រចាំឆ្នាំ

២- បទល្មើសព្រហ្មទណ្ឌនិងការបង្ក្រាបប្រចាំឆ្នាំ បទល្មើសព្រហ្មទណ្ឌនៅតាមសាលាដំបូង និងបទល្មើសព្រហ្មទណ្ឌលើ អនីតិជន

៣-អង្គការដៃគូនិងអង្គការមិនមែនរដ្ឋាភិបាលប្រចាំឆ្នាំ ដែលបានចុះអនុស្សារណៈលើការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាប្រចាំឆ្នាំ។ល។

- រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ០១.សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្ដីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធិភាពនៃការងារអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយធ្វើការពង្រឹងគោលការណ៍បណ្ដុះបណ្ដាលប្រកបដោយសមធម៌ ដោយយកចិត្តទុកដាក់ដល់ជនបាត់បង់ឱកាសឬមានឱកាសតិចតួចនៅក្នុងសង្គម និងសិស្សដែលបានបោះបង់ការសិក្សា។
- ក្រសួងយុត្តិធម៌បានចេញសេចក្ដីសម្រេចលេខ ០១ កយ.សសរ/១១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ ស្ដីពីការបង្កើតអាជ្ញាធរកណ្ដាលដែលមានតួនាទីជាអង្គភាពបង្គោល ដើម្បីសម្របសម្រួលការជួយគ្នាទៅវិញទៅមកក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌ រួមទាំងការធ្វើបត្យាប័នផង។
- ក្រសួង ស.អ.យ កំពុងដំណើរការតាក់តែង និងពិនិត្យសេចក្ដីព្រាងច្បាប់ស្ដីពីរបបសន្តិសុខសង្គម។
- សេចក្ដីព្រាងអនុក្រឹត្យស្ដីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ កំពុងឆ្លងកាត់ការពិនិត្យ និងអនុម័តពីគណៈរដ្ឋមន្ត្រី។
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារកំពុងដឹកនាំធ្វើការស្រាវជ្រាវវិភាគរកចំណុចចន្លោះខ្វះខាតនៅក្នុងក្របខ័ណ្ឌច្បាប់ជាតិទាក់ទងនឹងកិច្ចការពារកុមារ ប្រៀបធៀបទៅនឹងអនុសញ្ញាស្ដីពីសិទ្ធិកុមារនិងបទដ្ឋានអន្តរជាតិផ្សេងៗទៀត ក្នុងគោលបំណងអភិវឌ្ឍឡើងនូវកម្មវិធីអាទិភាពខាងផ្លូវច្បាប់មួយ ក្នុងកិច្ចការពារកុមារ និងរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីកិច្ចការពារកុមារ ប្រសិនបើអាចធ្វើទៅបាន ។

**ខ- ស្ថាប័នថ្មីៗ(រួមទាំងអាណត្តិរបស់ស្ថាប័នទាំងនោះ) ឬ ការធ្វើកំណែទម្រង់ស្ថាប័ន**

- ព្រះរាជានៃព្រះរាជាណាចក្រកម្ពុជាទ្រង់បានចេញព្រះរាជក្រឹត្យលេខ នស/រកម/១២០៩/១២០១ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការរៀបចំបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលមានរចនាសម្ព័ន្ធបន្តនៅតាមរាជធានី ខេត្ត និងតម្រូវឲ្យក្រសួងនីមួយៗរៀបចំឲ្យមានជាក្រុមការងារកុមារមួយឡើង ។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០ ដើម្បីធ្វើការកំណែទម្រង់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចេញប្រកាសលេខ ៧១០ ស.អ.យ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១០ ដើម្បីបង្កើតសាលាជាតិសង្គមកិច្ច។ សាលានេះផ្ដល់ការបណ្ដុះបណ្ដាលជំនាញ

សង្គមកិច្ច ក្នុងនោះរួមមានបណ្តុះបណ្តាលអំពីការអនុវត្តច្បាប់ស្តីពីសុំកូនអន្តរប្រទេស ច្បាប់ស្តីពីអនីតិជនទំនាស់នឹងច្បាប់ និងច្បាប់ផ្សេងៗទៀតទាក់ទងនឹងវិស័យសង្គមកិច្ច។

**គ-គោលនយោបាយ កម្មវិធី និងផែនការសកម្មភាព**

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ត្រូវបានអនុម័ត ដើម្បីសម្រេចឲ្យបាននូវគោលដៅអាទិភាពចំនួន ០២ របស់រាជរដ្ឋាភិបាលគឺ :

  **គោលដៅទី១**: បន្សីអាណត្តិកាលរបស់ផែនការនេះជាមួយអាណត្តិកាលរបស់រាជរដ្ឋាភិបាលសំដៅធានាថាសកម្មភាពដែលបាលគ្រោងទុកទាំងឡាយរបស់ក្រសួងស្ថាប័នទាំងអស់ត្រូវបានរៀបចំឡើងដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និង

  **គោលដៅទី២** : ដើម្បីធានាថាការងារដែលត្រូវលើកឡើងដោយក្រសួង-ស្ថាប័ន ពាក់ព័ន្ធដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ត្រូវបានរៀបចំឡើងដោយមានការគិតគូរដល់ផលប៉ះពាល់នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក។

- ផែនការជាតិលើកទី០២ ប្រឆាំងការជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ២០១១-២០១៤ បានរៀបចំរួចរាល់ និងរង់ចាំការសម្រេចពីរាជរដ្ឋាភិបាល។

**ឃ- ការផ្តល់សច្ចាប័នថ្មីៗលើឧបករណ៍សិទ្ធិមនុស្សផ្សេងៗទៀត**

គិតចាប់ពីពេលដែលព្រះរាជាណាចក្រកម្ពុជាបានបញ្ជូនរបាយការណ៍លើកទី២ និងលើកទី៣ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ(២០០០-២០០៧) រហូតមកដល់ត្រីមាសទី១ ឆ្នាំ២០១១នេះ កម្ពុជាពុំទាន់បានផ្តល់សច្ចាប័នលើឧបករណ៍សិទ្ធិមនុស្សផ្សេងៗទៀតនៅឡើយទេ។

# ផ្នែកទី៣

***ទិន្នន័យ ស្ថិតិ និងព័ត៌មានផ្សេងៗទៀត ប្រសិនបើមាន***

*១- សូមផ្តល់ស្ថិតិបំបែកតាមប្រភេទ ដូចជាតាមប្រភព តាមអាយុ និងភេទ របស់កុមារដែលគ្មានប្រទេស/សញ្ជាតិ និង កុមារដែលត្រូវបានបដិសេធមិនផ្តល់ឯកសារអត្តសញ្ញាណ។*

**ចម្លើយ** :

ពុំមានទិន្នន័យ តាមប្រភព តាមអាយុ និងភេទ របស់កុមារដែលគ្មានប្រទេស/សញ្ជាតិ និង កុមារដែលត្រូវបានបដិសេធមិនផ្តល់ឯកសារអត្តសញ្ញាណទេ។

*២- សូមផ្តល់ទិន្នន័យសម្រាប់ឆ្នាំ២០០៨, ២០០៩និង២០១០ បំបែកតាមប្រភេទ មាន អាយុ ភេទ ទីតាំងភូមិសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចនៃចំនួនកុមារដែលគ្មានការថែទាំពីឪពុកម្តាយ គិតជាភាគរយ ធៀបទៅនឹងកុមារទាំងអស់ និងបំបែកទៅតាមប្រភេទនៃការថែទាំដែលពួកគេទទួលបាន (ថែទាំក្នុងស្ថាប័ន ថែទាំតាមបែបក្នុងគ្រួសារ ។ល។)។*

**ចម្លើយ** :

សូមមើលការឆ្លើយតបចំពោះសំណួរទី៧ (ផ្នែកទី១)។

*៣- សូមផ្តល់ទិន្នន័យដែលប្រមូលបានតាមរយៈការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០១០ ជាពិសេសគឺទាក់ទងទៅនឹងស្ថានភាពអាហារូបត្ថម្ភរបស់កុមារ កុមារដែលផ្ទុកមេរោគអេដស៍ សុខភាពយុវវ័យ និងមរណភាពមាតា។*

**ចម្លើយ** :

សូមមើលការឆ្លើយតបចំពោះសំណួរទី១១ (ផ្នែកទី១)។

*៤- សូមផ្តល់ទិន្នន័យសម្រាប់ឆ្នាំ២០០៨ ២០០៩ និង២០១០ អំពីចំនួននយោជកដែលត្រូវបានចោទប្រកាន់ពីបទបំពារបំពានបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងពលកម្មកុមារ។*

**ចម្លើយ** :

១- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈលើកកម្ពស់សិទ្ធិកុមារតាមរយៈការអនុវត្ត :

- គោលនយោបាយរបស់រដ្ឋាភិបាល ផែនការសកម្មភាពរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពកម្មកុមារ(២០០៨-២០១២)។
- អនុសញ្ញាស្តីពីសិទ្ធិកុមារ
- ច្បាប់ស្តីពីការងារ **និងប្រកាសពាក់ព័ន្ធនឹងពលកម្មកុមាររបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**
- អនុសញ្ញាលេខ១៣៨ របស់អង្គការអន្តរជាតិខាងការងារស្តីពីការកំរិតអាយុអប្បបរមាសំរាប់ការចូលធ្វើការងារ
- អនុសញ្ញាលេខ១៨២ របស់អង្គការអន្តរជាតិខាងការងារស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សំរាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- អនុសញ្ញាលេខ២៩ របស់អង្គការអន្តរជាតិខាងការងារ ស្តីពីការងារដោយបង្ខំ ឬជាកាតព្វកិច្ច។

២- ចំនួននិយោជកត្រូវបានចោទប្រកាន់ពីបទបំពារបំពានបទ្បបញ្ញត្តិច្បាប់ទាក់ទងនឹងពលកម្មកុមារ :

| **ឆ្នាំ** | **និយោជកត្រូវបានចោទប្រកាន់** | **សំគាល់** |
|---|---|---|
| ២០០៨ | ០១ ករណី | អាយុអប្បបរមាអាចបម្រើការងារគឺ១៥ឆ្នាំ។ |
| ២០០៩ | ០១ ករណី | |
| ២០១០ | គ្មាន | |

*៥- សូមផ្តល់ទិន្នន័យសម្រាប់ឆ្នាំ២០០៨, ២០០៩និង២០១០ អំពី:*

*ក- ចំនួនកុមាររងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ រួមទាំងពេស្យាចារ្យ រូបភាពអាសអាភាសកុមារ និងទេសចរណ៍ផ្លូវភេទកុមារ*

*ខ- ចំនួនកុមាររងគ្រោះដោយសារការជួញដូរ*

*គ- ចំនួនកុមាររងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ រួមទាំងសួន្ធការផង*

*ឃ- ចំនួនកុមារដែលទទួលបាននូវការធ្វើឲ្យសះជា/ការស្តារ(recovery) និងសេវាសមាហរណកម្មសង្គមដោយបញ្ជាក់ច្បាស់ប្រភេទនៃសេវាដែលបានផ្តល់ឲ្យ និង*

*ង- ដំណើរការក្តីតាមផ្លូវច្បាប់ប្រឆាំងនឹងជនល្មើសនៃបទល្មើសទាំងអស់នោះ ព្រមទាំងលទ្ធផលនៃដំណើរការក្តីនោះផងដែរ ក្នុងអំឡុងពេលដូចគ្នា។*

**ចម្លើយ** :

**ក-** ចំនួនជនរងគ្រោះដែលត្រូវបានសង្គ្រោះ និងជួយដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនពីឆ្នាំ២០០៨ ដល់ឆ្នាំ២០០៩ មាន៖

| | ២០០៨ | ២០០៩ |
|---|---|---|

| | | |
|---|---|---|
| ១-ចំនួនជនរងគ្រោះ ត្រូវបានសង្គ្រោះ / ជួយ៖ | | |
| - អាយុក្រោម១៥ឆ្នាំ | ១៥៥ | ១៩៨ |
| - អាយុពី១៥ ទៅ១៧ឆ្នាំ | ១១៩ | ១២៦ |
| - អាយុចាប់ពី១៨ឆ្នាំឡើង | ៦៧៣ | ៤៦៧ |
| - សរុប | ៩៤៧ | ៧៩១ |
| ២-ជំនួយដែលបានផ្ដល់ | | |
| - បញ្ជូនទៅក្រសួងស.អ.យ | ៣១៧ | ៧៤ |
| - បញ្ជូនទៅអង្គការមិនមែនរដ្ឋាភិបាល | ៨៨ | ៥៧ |
| - ប្រគល់ជូនគ្រួសារ | ៥៤៣ | ៦៦៩ |
| - សរុប | ៩៤៨ | ៨០០ |

(ប្រភពពី នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន)

គិតត្រឹមខែធ្នូ ឆ្នាំ ២០១០ បទល្មើសពាក់ព័ន្ធនឹងផ្លូវភេទកុមារ ក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និងសេពសន្ថវៈនៅតាមសាលាជម្រះក្តី ឆ្នាំ២០១០ សរុប ៣៣៨ ករណី ជនចាប់ចោទ ៣៥៩ នាក់ :

| ល.រ | ប្រភេទបទល្មើស | ចំនួនករណី | ចំនួនជនរងគ្រោះ | | ចំនួនជនជាប់ចោទសរុប | | |
|---|---|---|---|---|---|---|---|
| | | | អនីតិជន | នីតិជន | ឃុំខ្លួន | មិនឃុំ-គ្មានខ្លួន | ឲ្យនៅក្រៅឃុំ |
| ១ | មាត្រា២៦-សញ្ជារកម្ម | ២៤ | ២ | ២៩ | ២៧ | ១៩ | ៦ |
| ២ | មាត្រា២៧-ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ៦ | ២ | ៤ | ៥ | ១ | ៤ |
| ៣ | មាត្រា២៨- សញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមារ | ២ | ២ | ០ | ៣ | ០ | ០ |
| ៤ | មាត្រា៣២- ផ្ដល់កន្លែងសម្រាប់ធ្វើពេស្យាចារ | ១០ | ១ | ១០ | ១៩ | ៣ | ២ |
| ៥ | មាត្រា៣៣- បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | ០ | ០ | ០ | ០ | ០ | ០ |
| ៦ | មាត្រា៣៤- ការទិញពេស្យាចារកុមារ | ១១ | ២៦ | ០ | ១៨ | ២ | ៣ |
| ៧ | មាត្រា៣៥- អំពើអូសទាញពេស្យាចារកុមារ | ២ | ៥ | ០ | ៩ | ១ | ២ |
| ៨ | មាត្រា៣៦-ការឲ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ | ០ | ០ | ០ | ០ | ០ | ០ |
| ៩ | មាត្រា៣៧- កិច្ចសន្យានៃអំពើពេស្យាចារកុមារ | ០ | ០ | ០ | ០ | ០ | ០ |
| ១០ | មាត្រា៣៩-រូបភាព និងសម្ភារៈអាសអាភាស | ៥ | ២ | ៥ | ៧ | ១ | ១ |
| ១១ | មាត្រា៤១-រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ២ | ១ | ០ | ២ | ០ | ០ |
| ១២ | មាត្រា៤២- អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ | ៣៧ | ៤០ | ២ | ២៨ | ៥ | ៨ |
| ១៣ | មាត្រា៤៣- អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ឆ្នាំ | ៦ | ៧ | ០ | ៦ | ១ | ០ |
| ១៤ | បទល្មើសរំលោភសេពសន្ថវៈ - សម្រេច | ១៨៥ | ៩២ | ៨៥ | ៦៨ | ៣៨ | ២២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៥ | បទល្មើសរំលោភសេពសន្ថវៈ - មិនសម្រេច(ប៉ុនប៉ង) | ៤៥ | ១៦ | ២៩ | ២០ | ១៥ | ១០ |
| ១៦ | បទល្មើសប្រទូស្តកេរ្តិ៍ខ្មាស | ៣ | ២ | ១ | ១ | ១ | ១ |
| **សរុប** | | **៣៣៨** | **១៩៨** | **១៦៥** | **២១៣** | **៨៧** | **៥៩** |

(ប្រភពពី ក្រសួងយុត្តិធម៌)

*ជនរងគ្រោះត្រូវបានបញ្ជូនទៅមន្ទីរ ស.អ.យ ធានី ខេត្ត ចំនួន៣៥១នាក់ អង្គការមិនមែនរដ្ឋាភិបាល ចំនួន១៣នាក់ និងគ្រួសារឬអ្នកអាណាព្យាបាលចំនួន ៨០៨នាក់។*

**ខ-** ពុំមានតួលេខស្តីពីទោសចរណ៍ផ្លូវភេទលើកុមារឡើយ ព្រោះក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទមិនបានកំណត់បទល្មើសផ្លូវភេទផ្អែកលើស្ថានភាពជាអ្នកទេសចរឡើយ។

**គ-** ចំនួនកុមាររងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ រួមទាំងសន្ទនការផង មាននៅក្នុងចំណោមបទល្មើសទាក់ទងនឹងអំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ បទរំលោភសេពសន្ថវៈ និងបទរួមភេទជាមួយអនីតិជនដោយបុព្វញាតិ ជាអាទិ៍។

**ឃ-** ចំនួនកុមារទទួលបាននូវការធ្វើឲ្យសះជា / ការស្តារនិងសេវាសមាហរណកម្មសង្គម

**សូមមើលការឆ្លើយតប ផ្នែកទី ៣ សំណួរទី ៥ ចំណុច ក**

*៦- សូមផ្តល់ស្ថិតិលំអិតសម្រាប់ឆ្នាំ២០០៨, ២០០៩និង២០១០ បំបែកតាមអាយុ ភេទ និងប្រភេទបទល្មើស លើ :*

*ក- ចំនួនកុមារដែលត្រូវបានកាត់ទោសដូចជាមនុស្សចាស់*

*ខ- ចំនួនកុមារដែលត្រូវបានឃុំឃាំងនៅក្នុងពន្ធនាគារមនុស្សចាស់*

*គ- ចំនួនកុមារទំនាស់នឹងច្បាប់ដែលបានទទួលទណ្ឌកម្មជំនួស*

*ឃ- ចំនួនករណីដែលបានរាយការណ៍ថាបានរងការបំពានឬថៃទាំមិនល្អនៅក្នុងអំឡុងពេលនៃការចាប់/ឃាត់ខ្លួន ឬការឃុំខ្លួនកុមារទំនាស់នឹងច្បាប់ ក៏ដូចជាអំពីប្រភេទនៃការតាមដានបន្ត ចំពោះករណី ទាំងអស់នោះផងដែរ។*

**ចម្លើយ** :

**ក-** ចំនួនកុមារដែលត្រូវបានកាត់ទោសដូចជាមនុស្សចាស់ :

- សូមមើលការឆ្លើយតបចំពោះសំណួរទី១៧(ផ្នែកទី១)។
- ព្រះរាជាណាចក្រកម្ពុជាកំពុងប្រឹងប្រែងធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌កុមារជំទូលំទូលាយ។ ដូច្នេះនៅមិនទាន់មានច្បាប់ និងតុលាការពិសេសសម្រាប់ចាត់ការ និងជំនុំជម្រះរឿងក្តីអនីតិជនទំនាស់នឹងច្បាប់ទេ។ នីតិវិធីសម្រាប់មនុស្សចាស់អនុវត្តចំពោះកុមារ លើកលែងតែករណីមានបទប្បញ្ញត្តិពិសេសដែលកំណត់ដោយច្បាប់។ ការប្រព្រឹត្តិផ្សេងទៅលើកុមារទំនាស់នឹងច្បាប់មានចែងនៅក្នុងក្រមព្រហ្មទណ្ឌថ្មី ជាពិសេសក្នុងមាត្រាលេខ៣៩ (វិធានការសម្រាប់អនុវត្តចំពោះអនីតិជន) មាត្រា

លេខ៤០(ប្រភេទវិធានការ) និងមាត្រាលេខ៤១៦០ (ទណ្ឌកម្មគោលសម្រាប់អនុវត្តចំពោះអនីតិជនមានអាយុលើសពី១៨ឆ្នាំ)។

**ខ-** ចំនួនកុមារដែលត្រូវបានឃុំឃាំងនៅក្នុងពន្ធនាគារមនុស្សចាស់ :

មិនទាន់មានច្បាប់ពិសេសដែលចែងពីពន្ធនាគារ និងមណ្ឌលអប់រំអនីតិជនទំនាស់នឹងច្បាប់ទេ។ នីតិវិធីសម្រាប់មនុស្សចាស់អនុវត្តចំពោះកុមារ លើកលែងតែករណីមានបទប្បញ្ញត្តិពិសេសដែលកំណត់ដោយច្បាប់។ មណ្ឌលកែប្រែទី០២ព្រៃស គឺជាមជ្ឈមណ្ឌលកែប្រែដោយឡែកសម្រាប់តែកុមារ។ នៅតាមពន្ធនាគារដទៃទៀត គេដាក់កុមារនៅក្នុងអគារ ស្លាប ឬបន្ទប់ផ្សេងពីមនុស្សចាស់ លើកលែងតែនៅក្នុងពន្ធនាគារមួយចំនួនតូចដែលមានមនុស្សជាប់ឃុំច្រើនហួសពេក ។

**ចំនួនកុមារក្នុងពន្ធនាគារ ឆ្នាំ២០០៨ ដល់ ឆ្នាំ២០១០**

| ឆ្នាំ | អនីតិជនសរុប | ស្រី |
|---|---|---|
| ២០០៨ | ៤៦៥ | ២៤ |
| ២០០៩ | ៨៤០ | ២៧ |
| ២០១០ | ៧៣០ | ២៦ |

(ប្រភពពី **អគ្គនាយកដ្ឋានពន្ធនាគារ**)

**គ-** ចំនួនកុមារទំនាស់នឹងច្បាប់ដែលបានទទួលទណ្ឌកម្មជំនួស :

ព្រះរាជាណាចក្រកម្ពុជាកំពុងប្រឹងប្រែងបង្កើតប្រព័ន្ធទិន្នន័យស្តីពីយុត្តិធម៌កុមារដែលអាចផ្តល់ទិន្នន័យស្តីពីកុមាររងគ្រោះពីបទល្មើសផ្លូវភេទ និងកុមារល្មើសច្បាប់ នៅដំណាក់កាលស៊ើបអង្កេត និងជំនុំជម្រះ។ រហូតមកដល់ពេលនេះ ប្រព័ន្ធទិន្នន័យនេះនៅមិនទាន់អាចផ្តល់តួលេខជាផ្លូវការ អំពីចំនួនកុមារទំនាស់នឹងច្បាប់ដែលបានទទួលទណ្ឌកម្មជំនួសនៅឡើយទេ។

ចាប់តាំងពីឆ្នាំ២០០៨មក ក្នុងខេត្តចំនួន៥នៃព្រះរាជាណាចក្រកម្ពុជា មានការអនុវត្តកម្មវិធីតាមសហគមន៍ ដើម្បីបង្ការ និងស្តារនីតិសម្បទាអនីតិជនដែលប្រព្រឹត្តបទល្មើសលហុ តាមរយៈសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន២។ កម្មវិធីនេះសហការជាមួយនឹងក្រុមប្រឹក្សាឃុំ និងអាជ្ញាធរមូលដ្ឋានដទៃទៀត ក្នុងការបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ បំណិនជីវិត ជំនាញវិជ្ជាជីវៈ និងការគ្រប់គ្រងកំហឹងជាដើមដល់កុមារស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ជាង១០០០នាក់ ព្រមទាំងតាមដានការបង្វែរអនីតិជនចេញពីប្រព័ន្ធតុលាការ និងជម្រើសនានាសម្រាប់កុមារល្មើសនឹងច្បាប់ ចំនួនច្រើនជាង១០០នាក់ត្រឹមចុងឆ្នាំ២០១០។

**ឃ-** សូមមើលការឆ្លើយតបចំពោះសំណួរទី១៥ នៃផ្នែកទី១ (កឋាខណ្ឌទី២ ចំណុចទី៥ )។

ពុំមានបណ្តឹងដែលបានរាយការណ៍ថាបានរងការបំពានឬថៃទាំមិនល្អនៅក្នុងអំឡុងពេលនៃការចាប់/ឃាត់ខ្លួន ឬការឃុំខ្លួនកុមារទំនាស់នឹងច្បាប់ ក៏ដូចជាអំពីប្រភេទនៃការតាមដានបន្តចំពោះករណីទាំងអស់នោះផងដែរ។

*៧- សូមផ្តល់ជូនគណៈកម្មាធិការនូវព័ត៌មានបច្ចុប្បន្នកម្មស្តីពីទិន្នន័យដែលមាននៅក្នុងរបាយការណ៍ដែលជាព័ត៌មានចាស់ ដោយតួលេខទើបប្រមូលបានថ្មីៗ ឬមានការអភិវឌ្ឍន៍អ្វីថ្មីទៀត។*

**ចម្លើយ :**

សូមមើល :

១- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ (**ឧបសម្ព័ន្ធទី ២**)។

២- របាយការណ៍បូកសរុបពិនិត្យឡើងវិញនូវការងារពាក់កណ្តាលអាណត្តិកម្មវិធី ឆ្នាំ២០០៦-២០១០និង

៣- របាយការណ៍របស់ព្រះរាជាណាចក្រកម្ពុជាស្តីពីការអនុវត្តសេចក្តីសម្រេចចិត្តលេខ២០០៩/២៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិស្តីពី ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិ និងអន្តរជាតិដើម្បីកំណែទម្រង់យុត្តិធមិកុមារ(ឧបសម្ព័ន្ធទី៣)។

*៨- រដ្ឋភាគីក៏អាចរៀបរាប់បន្ថែមបានដែរនូវវិស័យដែលមានការប៉ះពាល់មកលើកុមារ ដែលខ្លួនគិតថា ជាអាទិភាព ទាក់ទងទៅនឹងការអនុវត្តអនុសញ្ញា។*

**ចម្លើយ :**

វិស័យដែលមានការប៉ះពាល់មកលើកុមារដែលជាអាទិភាពទាក់ទងទៅនឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារគឺការអនុវត្តមាត្រា៣៤ នៃរដ្ឋធម្មនុញ្ញ ដែលបានចែងថា : រដ្ឋភាគីរ៉ាប់រងការពារកុមារឲ្យផុតពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ។ ក្នុងទិសដៅនេះព្រះរាជាចក្រកម្ពុជាចាត់វិធានការសមស្របនានាក្នុងក្របខ័ណ្ឌជាតិ ទ្វេភាគី និងពហុភាគីដើម្បីបង្ក្រាប និងបង្ការ :

(ក) ការអូសទាញឬការបង្ខិតបង្ខំកុមារឲ្យចូលរួមក្នុងសកម្មភាពខាងផ្លូវភេទ។

(ខ) ការប្រើប្រាស់កុមារក្នុងពេស្យាកម្មឬការប្រព្រឹត្តដោយខុសច្បាប់ខាងផ្លូវភេទផ្សេងទៀត ។

(គ) ការប្រើប្រាស់កុមារក្នុងការសម្តែងអំពើអាសអាភាស និងការផលិតសម្ភារៈឬរូបភាពអាសអាភាស ។

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១:** របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលនៃការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារឆ្នាំ២០១១និងទិសដៅឆ្នាំ២០១១។

**ឧបសម្ព័ន្ធទី ២:** ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។

**ឧបសម្ព័ន្ធទី៣:** របាយការណ៍របស់ព្រះរាជាចក្រកម្ពុជាស្តីពីការអនុវត្តសេចក្តីសម្រេចចិត្តលេខ២០០៩/២៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិស្តីពី៉ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិ និងអន្តរជាតិដើម្បីកំណែទម្រង់យុត្តិធម៌កុមារ។

# ឯកសារយោង


1. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។
2. របាយការណ៍បូកសរុបពិនិត្យឡើងវិញនូវការងារពាក់កណ្ដាលអាណត្តិកម្មវិធី ឆ្នាំ២០០៦-២០១០និង
3. របាយការណ៍របស់ព្រះរាជាចក្រកម្ពុជាស្ដីពីការអនុវត្តសេចក្ដីសម្រេចចិត្តលេខ២០០៩/២៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិស្ដីពី៉ ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិ និងអន្តរជាតិដើម្បីកំណែទម្រង់យុត្តិធម៌កុមារ។
4. យុទ្ធសាស្ត្ររស់រានមានជីវិតរបស់កុមារ ឆ្នាំ២០០៦
5. អង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ឆ្នាំ២០០០និង២០០៥
6. របាយការណ៍ប្រចាំឆ្នាំ២០១០បណ្ដោះអាសន្នរបស់កម្មវិធីសុខភាពបន្តពូជនិងថែទាំទារក
7. របាយការណ៍ប្រចាំឆ្នាំ២០១០ របស់មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
8. របាយការណ៍ប្រចាំឆ្នាំ២០១០របស់កម្មវិធីបង្ការការចម្លងរោគពីមាតាទៅទារក PMTCT
9. របាយការណ៍ប្រចាំឆ្នាំ២០១០របស់កម្មវិធីអាហារូបត្ថម្ភជាតិ (NNP)
10. របាយការណ៍ប្រចាំឆ្នាំ២០១០របស់នាយកដ្ឋានត្រួតពិនិត្យជំងឺឆ្លង (CDC) និង
11. **ឯកសារផ្សេងទៀត ដូចជារបាយការណ៍របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរាជកិច្ច ជាអាទិ៍។**